សាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច
Université Royale de Droit et des Sciences Economiques
Royal University of Law and Economics

## សារណាបញ្ចប់ការសិក្សា

# ដំណើរការនីតិវិធីរឿងក្តីព្រហ្មទណ្ឌ នៅសាលាដំបូងរាជធានី-ខេត្ត

ស្រាវជ្រាវពីថ្ងៃទី១៨ ខែមីនា ឆ្នាំ២០១៩ ដល់ថ្ងៃទី១៦ ខែឧសភា ឆ្នាំ២០១៩

ស្រាវជ្រាវដោយ

និស្សិតឈ្មោះ លោក **ហៃ លីហៀង**

លោក **សេង សំណាង**

សាស្ត្រាចារ្យណែនាំ

លោក **ជួន ម៉ុនធី**

ថ្នាក់បរិញ្ញាបត្រ **នីតិសាស្ត្រ**

ជំនាន់ទី ១៩

ឆ្នាំចូលសិក្សា ២០១៥

ឆ្នាំសរសេរសារណា ២០១៩

# សេចក្តីថ្លែងអំណរគុណ

ខ្ញុំបាទ **ហៃ លីហៀង** និង **សេង សំណាង** ជានិស្សិតនៃសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច ថ្នាក់បរិញ្ញាបត្រនីតិសាស្ត្រឆ្នាំទី៤ ជំនាន់ទី១៩ ឆ្នាំសិក្សា២០១៨-២០១៩។

**<u>សូមថ្លែងអំណរគុណ</u>**

- ចំពោះ មាតា បិតា ដែលលោកបានបង្កើតរូបកាយកូន និងចិញ្ចឹមបីបាច់ថែរក្សា អប់រំទូន្មាន ឧបត្ថម្ភរូបកូនគ្រប់បែបយ៉ាងតាំងពីតូចដល់ធំ ទាំងកម្លាំងកាយ ទាំងកម្លាំងចិត្តមិនគិតពីការនឿយហត់របស់លោកទាំងពីរនោះឡើយ និងបានឲ្យកូនរៀនសូត្រមានចំណេះដឹងរហូតដល់បញ្ចប់ថ្នាក់បរិញ្ញាបត្រដោយជោគជ័យ។ គុណូបការៈយ៉ាងធំអនេក និងវិសេសវិសាលថ្លៃថ្លាបំផុតដែលមិនអាចកាត់ថ្លៃបានរបស់លោកអ្នកមានគុណទាំងពីរដែលជាម្លប់ដ៏ប្រពៃត្រជាក់ត្រជុំសម្រាប់កូនគ្រប់ៗរូបមានទំហំធំធេងរកអ្វីប្រៀបផ្ទឹមពុំបានឡើយ។ ទង្វើរបស់លោកទាំងពីរធ្វើឲ្យកូនៗចងចាំជានិច្ចគ្មានថ្ងៃបំភ្លេចបាន ហើយនឹងស្ថិតក្នុងដួងព្រលឹងរបស់កូនៗជារៀងដរាបគ្មានថ្ងៃសូន្យនោះឡើយ ។

- ចំពោះ ឯកឧត្តមសាកលវិទ្យាធិការដែលបានអនុញ្ញាតឲ្យយើងខ្ញុំបាទ បានសរសេររបាយការណ៍សារណាដើម្បីបានបញ្ចប់ការសិក្សារយៈពេលបួនឆ្នាំ និងដើម្បីទទួលបានសញ្ញាបត្រផ្នែកនីតិសាស្ត្រ ។

- ជាពិសេសយើងខ្ញុំសូមថ្លែងអំណរគុណចំពោះ លោកសាស្ត្រាចារ្យ **ជួន ម៉ុនធី** ដែលជាសាស្ត្រាចារ្យណែនាំ ដើម្បីធ្វើឲ្យមាននូវដំណើរការនៃការស្រាវជ្រាវសារណានេះឡើងប្រកបដោយភាពជោគជ័យ។ ជាពិសេសលោកបានចំណាយនូវកម្លាំងកាយ កម្លាំងចិត្ត និងពេលវេលាដ៏មានតម្លៃក្នុងការណែនាំ ប្រឹងប្រែងពន្យល់ តម្រង់ទិស ផ្តល់ឯកសារពាក់ព័ន្ធ និងអនុសាសន៍ល្អៗ និងជួយកែលម្អចំណុចខ្វះខាតទាំងឡាយ ដើម្បីធ្វើយ៉ាងណាឲ្យសារណាយើងខ្ញុំបានទទួលនូវលទ្ធផលល្អ និងត្រឹមត្រូវ ។

- ចំពោះ លោក-លោកស្រីសាស្ត្រាចារ្យដែលជាបុគ្គលិកនៃសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច ដែលបានផ្តល់នូវចំណេះដឹងដល់រូបខ្ញុំបាទតាំងពីថ្នាក់បរិញ្ញាបត្រមូលដ្ឋានរហូតមកដល់ពេលបញ្ចប់ថ្នាក់បរិញ្ញាបត្រឆ្នាំទី៤នេះ។ យើងខ្ញុំទាំងពីរនាក់ សូមជូនពរដល់លោក-លោកស្រីសាស្ត្រាចារ្យឲ្យជួបតែនឹងពុទ្ធពរទាំងបួនប្រការ គឺ អាយុ វណ្ណៈ សុខៈ ពលៈ កុំបីឃ្លៀងឃ្លាតឡើយ។

# អារម្ភកថា

ក្រោយពីបានបញ្ចប់ការសិក្សាអស់រយៈពេលបួនឆ្នាំ សាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច បានតម្រូវឲ្យយើងខ្ញុំជានិស្សិតចុះកម្មសិក្សា និងសរសេររបាយការណ៍សារណាដើម្បីបញ្ចប់ការសិក្សាថ្នាក់បរិញ្ញាបត្រផ្នែកនីតិសាស្ត្រនេះ និងដើម្បីទទួលបាននូវសញ្ញាបត្រនីតិសាស្ត្រប្រកបដោយជោគជ័យ។

ការលើកយកនូវប្រធានបទ ដំណើរការនីតិវិធីរឿងក្តីព្រហ្មទណ្ឌនៅសាលាដំបូងរាជធានី-ខេត្ត មកបកស្រាយបែបនេះ គឺមានបំណងចងក្រងទុកជាឯកសារដើម្បីឲ្យមិត្តនិស្សិតជំនាន់ក្រោយធ្វើការស្វែងយល់នូវដំណើរការនៃរឿងក្តីព្រហ្មទណ្ឌនៅសាលាជម្រះក្តីជាន់ទាប និងដើម្បីជាជំនួយក្នុងការខ្វះចន្លោះរបស់មិត្តនិស្សិត។

ការណែនាំយ៉ាងយកចិត្តទុកដាក់របស់លោកសាស្ត្រាចារ្យ **ជួន ម៉ុនធី** និងបានពឹងផ្អែកលើសៀវភៅមេរៀនរបស់លោក-លោកស្រីសាស្ត្រាចារ្យ ព្រមទាំងឯកសារមួយចំនួន ដែលទាំងអស់នេះហើយជាកត្តាដែលនាំឲ្យខ្ញុំបាទបានរបាយការណ៍សរសេរសារណានេះរហូតទទួលបានលទ្ធផលជាស្ថាពរ ។

ក្រោយពីការស្រាវជ្រាវបានបញ្ចប់ ខ្ញុំបាទសង្ឃឹមថាសារណានេះនឹងក្លាយជាអត្ថបទដែលមានសារៈប្រយោជន៍សម្រាប់អ្នកសិក្សាស្រាវជ្រាវផ្នែកច្បាប់ទាំងអស់ ជាពិសេសអ្នកអនុវត្តនីតិវិធីនៅតាមស្ថាប័នជម្រះក្តីនានា។ ជាងនេះទៅទៀត វាក៏អាចនឹងក្លាយជាឯកសារមួយដែលបានចូលរួមចំណែក និងជម្រុញដល់ការអនុវត្តច្បាប់ឲ្យកាន់តែមានប្រសិទ្ធភាព ហើយជាចំណែកនៃការផ្សព្វផ្សាយច្បាប់ និងការស្រាវជ្រាវផ្នែកនីតិវិធីព្រហ្មទណ្ឌឲ្យកាន់តែសម្បូរបែបផងដែរ ។

បើទោះបីជាមានការខិតខំស្រាវជ្រាវ និងការត្រួតពិនិត្យយ៉ាងហ្មត់ចត់យ៉ាងណាក៏ដោយ ក៏ការសរសេរសារណានេះពិតជាមានចំណុចមួយចំនួនដែលខ្វះខាត ដូចនេះយើងខ្ញុំទាំងពីរនាក់រង់ចាំទទួលការរិះគន់ពីសំណាក់លោក-លោកស្រីសាស្ត្រាចារ្យ សិស្ស និស្សិតទាំងអស់ ដើម្បីកែលម្អសារណានេះឲ្យកាន់តែមានលក្ខណៈល្អប្រសើរ។

# មាតិកា


ទំព័រ

សេចក្តីផ្តើម ........................................ ១

## ជំពូកទី១

## ចំណាត់ការលើបណ្តឹងព្រហ្មទណ្ឌ

ផ្នែកទី១៖ ការអនុវត្តលើបណ្តឹងព្រហ្មទណ្ឌ ........................................ ២

កថាខណ្ឌទី១៖ ការទទួលពាក្យបណ្តឹង និងការស៊ើបអង្កេត ........................................ ២

ក. ការទទួលពាក្យបណ្តឹង ........................................ ២

ខ. ការស៊ើបអង្កេត ........................................ ២

កថាខណ្ឌទី២៖ ចំណាត់ការរបស់អយ្យការ ........................................ ២

ក. ចំពោះបទល្មើសជាក់ស្តែង ........................................ ៣

ខ. ចំពោះបទល្មើសមិនជាក់ស្តែង ........................................ ៤

ផ្នែកទី២៖ ការចោទប្រកាន់របស់ព្រះរាជអាជ្ញា ........................................ ៥

កថាខណ្ឌទី១៖ ជម្រើសនៃការចោទប្រកាន់ ........................................ ៥

ក. ការប្តឹងទៅយុត្តាធិការស៊ើបសួរ ........................................ ៦

ខ. ការប្តឹងទៅយុត្តាធិការជំនុំជម្រះ ........................................ ៧

ខ.១. ការបង្ហាញខ្លួនភ្លាម ........................................ ៧

ខ.២. ដីកាកោះហៅបញ្ជូនទៅជំនុំជម្រះផ្ទាល់ ........................................ ៨

កថាខណ្ឌទី២៖ ជម្រើសផ្សេងពីការចោទប្រកាន់ ........................................ ៨

ក. ការតម្កល់រឿងទុកឥតចាត់ការ ........................................ ៩

ខ. ករណីមិនគួរចោទប្រកាន់ ........................................ ១០

## ជំពូកទី២

## នីតិវិធីនៃការស៊ើបសួរ

ផ្នែកទី១៖ ចៅក្រមស៊ើបសួរ ........................................ ១១

កថាខណ្ឌទី១៖ ការរៀបចំចៅក្រមស៊ើបសួរ ........................................ ១១

កថាខណ្ឌទី២៖ ការដកហូតសំណុំរឿងពីចៅក្រមស៊ើបសួរ ........................................ ១១

ផ្នែកទី២៖ ដំណើរការស៊ើបសួរ និងការបញ្ជូនលទ្ធផលនៃកិច្ចស៊ើបសួរទៅឲ្យព្រះរាជអាជ្ញា ........................................ ១១

កថាខណ្ឌទី១៖ ការបំពេញកិច្ចរបស់ចៅក្រមស៊ើបសួរ ..... ១១
ក. ការស្វែងរកអង្គហេតុពិត ..... ១២
ក.១. ករណីគ្មានបទល្មើស ..... ១២
ក.២. ករណីមានបទល្មើស ..... ១២
ខ. ការស្វែងរកភស្តុតាង ..... ១៣
ខ.១. ភស្តុតាងដាក់បន្ទុក ..... ១៣
ខ.២. ភស្តុតាងដោះបន្ទុក ..... ១៣
គ. វិធានការនិរន្តរាយ ..... ១៤
គ.១. ការសម្រេចឲ្យឃុំខ្លួន និងការអនុញ្ញាតឲ្យនៅក្រៅឃុំបណ្ដោះអាសន្ន ..... ១៤
គ.១.១. ការឃុំខ្លួនបណ្ដោះអាសន្ន ..... ១៤
គ.១.២. ការអនុញ្ញាតឲ្យនៅក្រៅឃុំបណ្ដោះអាសន្ន ..... ១៧
គ.២. ការកោះហៅឲ្យមកបង្ហាញខ្លួន ..... ១៩
គ.២.១. ដីកាកោះហៅ ..... ២០
គ.២.២. ដីកាបង្គាប់ឲ្យចូលខ្លួន ..... ២០
គ.២.៣. ដីកាបង្គាប់ឲ្យនាំខ្លួន ..... ២១
គ.២.៤. ដីកាបង្គាប់ឲ្យចាប់ខ្លួន ..... ២២
កថាខណ្ឌទី២៖ ការបញ្ជូនលទ្ធផលស៊ើបសួរទៅឲ្យព្រះរាជអាជ្ញាពិនិត្យ ..... ២៤
ផ្នែកទី៣៖ ការបិទការស៊ើបសួររបស់ចៅក្រមស៊ើបសួរ ..... ២៥
កថាខណ្ឌទី១៖ ការបញ្ចប់ការស៊ើបសួរ ..... ២៥
ក. ការជូនដំណឹងទៅភាគី ..... ២៥
ក.១. ការសន្និដ្ឋានរបស់អយ្យការចំពោះលទ្ធផលរបស់ចៅក្រមស៊ើបសួរ ..... ២៥
ក.២. ដីកាសន្និដ្ឋានស្ថាពររបស់ព្រះរាជអាជ្ញា ..... ២៥
ខ. ការសម្រេចរបស់ចៅក្រមស៊ើបសួរ ..... ២៦
កថាខណ្ឌទី២៖ ការសម្រេចដោយដីកាដំណោះស្រាយ ..... ២៧
ក. ការលើកលែងការចោទប្រកាន់ ..... ២៨
ខ. ការបញ្ជូនខ្លួនជនជាប់ចោទទៅជំនុំជម្រះ ..... ២៨

## ជំពូកទី៣

## ដំណើរការនៃការជំនុំជម្រះ

ផ្នែកទី១៖ នីតិវិធីនៃការរៀបចំជំនុំជម្រះ ..... ៣០

**កថាខណ្ឌទី១៖ ការរៀបចំតុលាការ** ....................................................... ៣០
**ក. ការដកខ្លួនដោយឯកឯង** ....................................................... ៣០
**ខ. បណ្តឹងជំទាស់** ....................................................... ៣០
**កថាខណ្ឌទី២៖ ការរៀបចំសវនាការជំនុំជម្រះ** ....................................................... ៣១
**ក. បទបញ្ជា** ....................................................... ៣១
**ខ. នីតិវិធីនៃការជំនុំជម្រះ** ....................................................... ៣២
**ផ្នែកទី២៖ សាលក្រម** ....................................................... ៣៥
**កថាខណ្ឌទី១៖ ប្រភេទនៃសាលក្រម** ....................................................... ៣៥
**ក. សាលក្រមចំពោះមុខ** ....................................................... ៣៥
**ខ. សាលក្រមចាត់ទុកជាចំពោះមុខ** ....................................................... ៣៥
**គ. សាលក្រមកំបាំងមុខ** ....................................................... ៣៥
**ឃ. សាលក្រមចាត់របៀប** ....................................................... ៣៦
**កថាខណ្ឌទី២៖ អានុភាពនៃសាលក្រម** ....................................................... ៣៦
**ក. ខ្លឹមសារនៃសាលក្រម** ....................................................... ៣៦
**ខ. ការប្រកាសសាលក្រម** ....................................................... ៣៧
**សេចក្តីសន្និដ្ឋាន** ....................................................... ៣៨
**ការផ្តល់អនុសាសន៍** ....................................................... ៤០
**ឯកសារពិគ្រោះ**
**ឧបសម្ព័ន្ធ**

# សេចក្តីផ្តើម

កាលពីសម័យមុនមនុស្សរស់នៅដោយប្រាស្រ័យជាមួយច្បាប់ធម្មជាតិ តែដល់ក្រោយៗមក កំណើតមនុស្សចេះតែកើនឡើង ហើយធម្មជាតិក៏ចាប់ផ្តើមវិនាសបន្តិចម្តងៗ ចំណែកឯសង្គមមនុស្សក៏មានការប្រកួតប្រជែងដណ្តើមផលប្រយោជន៍គ្នាដើម្បីបំពេញនូវសេចក្តីត្រូវការឥតព្រំដែន យ៉ាងអាណាធិបតេយ្យ គ្មានសណ្តាប់ធ្នាប់ បាត់បង់សីលធម៌ បែកបាក់សាមគ្គីភាព។ល។

ទាំងអស់នេះហើយ ដែលជាមូលហេតុបណ្តាលឲ្យមានអំពើល្មើសកើតមាននៅក្នុងសង្គម ដូចជា អំពើកាប់សម្លាប់ លួច ឆក់ ប្លន់ ចាប់រំលោភ ចាប់ជំរិតទារយកប្រាក់ ឬសម្ភារៈផ្សេងៗ និងអំពើល្មើសជាច្រើនទៀតតាមទំនើងចិត្តដោយមិនខ្វល់ពីទុក្ខវេទនារបស់ប្រជាជនស្លូតត្រង់ និងបានបង្កឲ្យមានផលវិបាកដល់សង្គមជាតិទាំងមូលផងដែរ។ ដូច្នេះហើយទើបអ្នកដឹកនាំប្រទេសទាំងឡាយលើពិភពលោកធ្វើការរិះរកគ្រប់មធ្យោបាយ ដើម្បីបង្ការ និងទប់ស្កាត់នូវអំពើអសកម្មទាំងនោះដោយបានរៀបចំតាក់តែង និងបានបង្កើតនូវលិខិតបទដ្ឋានគតិយុត្តជាច្រើនដើម្បីគ្រប់គ្រងកុំឲ្យមានបទល្មើសទាំងអស់នេះកើតមានឡើងនៅក្នុងសង្គមដែនដីរបស់ខ្លួន។

ដោយឡែកនៅក្នុងព្រះរាជាណាចក្រកម្ពុជាយើងវិញ ក៏បានតាក់តែងឡើងនូវលិខិតបទដ្ឋានគតិយុត្តជាច្រើនដែលប្រកាន់យកលទ្ធិប្រជាធិបតេយ្យដោយឈរលើគោលការណ៍គោរពសិទ្ធិ សេរីភាពដល់ប្រជាពលរដ្ឋ ដែលនៅក្នុងនោះរួមមាន៖ ក្រមនីតិវិធីព្រហ្មទណ្ឌ ដែលត្រូវបានអនុម័តដោយរដ្ឋសភានៅថ្ងៃទី៧ ខែមិថុនា ឆ្នាំ២០០៧ និងត្រូវបានប្រកាសឲ្យប្រើតាមព្រះរាជក្រមលេខ នស\រកម\០៨០\០២៤ ចុះថ្ងៃទី១០ ខែសីហា ឆ្នាំ២០០៧ ដើម្បីជាយន្តការការពារសិទ្ធិសេរីភាពរបស់ប្រជាពលរដ្ឋក្នុងការស្វែងរកយុត្តិធម៌តាមផ្លូវតុលាការ ជៀសវាងការទាមទារយុត្តិធម៌ក្រៅផ្លូវតុលាការ ។

នីតិវិធីព្រហ្មទណ្ឌ គឺសំដៅលើបណ្តុំនៃវិធានដែលកំណត់ពីបុគ្គលិកលក្ខណៈ និងសកម្មភាពរបស់តុលាការព្រហ្មទណ្ឌចាប់ពីពេលដែលមានការសង្ស័យ ពីការប្រព្រឹត្តបទល្មើសរហូតដល់ពេលដែលចារីត្រូវបានកំណត់អត្តសញ្ញាណ និងត្រូវបានផ្តន្ទាទោសតាមច្បាប់ជាធរមាន។

នៅពេលមានបទល្មើសមួយកើតមានឡើង យើងសង្កេតឃើញថាមានការចាប់ផ្តើមនូវកិច្ចនីតិវិធីជាច្រើនត្រូវបានអនុវត្តដោយអាជ្ញាធរមានសមត្ថកិច្ចស្រមតាមវិធាននៃក្រមនីតិវិធីព្រហ្មទណ្ឌ និងក្រមព្រហ្មទណ្ឌ ដើម្បីធ្វើការកំណត់អំពីអត្ថិភាព ឬនត្ថិភាព នៃបទល្មើស និងបញ្ឈប់សកម្មភាពនៃបទល្មើសនោះតាមច្បាប់ មុនពេលដែលជនល្មើសត្រូវបានផ្តន្ទាទោសដោយតុលាការព្រហ្មទណ្ឌ។ ក្នុងនោះរួមមានដំណាក់កាលនីតិវិធីធំៗជាច្រើន ដែលត្រូវយកមកបង្ហាញជាបន្តបន្ទាប់ដូចតទៅ៖

# ជំពូកទី១

# ចំណាត់ការលើបណ្ដឹង

## ផ្នែកទី១៖ ការអនុវត្តលើបណ្ដឹង

### កថាខណ្ឌទី១៖ ការទទួលពាក្យបណ្ដឹង និងការស៊ើបអង្កេត

#### ក. ការទទួលពាក្យបណ្ដឹង

ព្រះរាជអាជ្ញាទទួលពាក្យបណ្ដឹងបរិហារ ឬបណ្ដឹងទាមទារពីប្រជាពលរដ្ឋ នគរបាលយុត្តិធម៌ ជនរងគ្រោះ ឬសាច់ញាតិជនរងគ្រោះ រដ្ឋមន្ត្រីក្រសួងយុត្តិធម៌ ព្រមទាំងមន្ត្រីផ្សេងៗទៀត។

ការទទួលបណ្ដឹងអាចជាការប្ដឹងផ្ទាល់មាត់ ឬរបាយការណ៍ ឬតាមរយៈកំណត់ហេតុដែលមានការរៀបរាប់អំពីបទល្មើស ព្រមទាំងមានអត្តសញ្ញាណរបស់បុគ្គលដែលពាក់ព័ន្ធ រួមទាំងកាលបរិច្ឆេទ។

ព្រះរាជអាជ្ញាអាចផ្ដើមធ្វើការស៊ើបអង្កេត ឬប្ដឹងទៅយុត្តាធិការស៊ើបសួរ ឬប្ដឹងទៅយុត្តាធិការជំនុំជម្រះបាន លុះត្រាតែព្រះរាជអាជ្ញាបានទទួលពាក្យបណ្ដឹង ឬដឹងពីអំពើទាំងឡាយដែលជាបទល្មើស ឬមានការចង្អុលបង្ហាញណាមួយជាមុនសិន ទោះបីជាបណ្ដឹងនោះជាបណ្ដឹងផ្ទាល់ ឬបណ្ដឹងតាមរយៈមន្ត្រីដែលពាក់ព័ន្ធផ្សេងទៀត។

#### ខ. ការស៊ើបអង្កេត

ក្នុងការស៊ើបអង្កេតព្រះរាជអាជ្ញា មានតួនាទីយ៉ាងសំខាន់ក្នុងការចាត់វិធានការធ្វើការស៊ើបអង្កេតចាំបាច់ដើម្បីពិនិត្យអំពីភស្តុតាងនានារបស់ជនសង្ស័យ។ នៅក្នុងគ្រប់ករណីបទឧក្រិដ្ឋ ព្រះរាជអាជ្ញាអាចចាត់វិធានការស៊ើបអង្កេតដោយខ្លួនឯង។ នៅក្នុងករណីបទឧក្រិដ្ឋ ឬមជ្ឈិមជាក់ស្ដែង និងមុនពេលដែលចៅក្រមស៊ើបសួរទទួលបានសំណុំរឿងហើយ ព្រះរាជអាជ្ញាអាចចេញបញ្ជានាំខ្លួនជនដែលពាក់ព័ន្ធផ្សេងៗ ដើម្បីស្ដាប់ចម្លើយ និងចាត់នីតិវិធីឆែកឆេរលំនៅឋានរបស់ជនសង្ស័យព្រមទាំងរឹបអូសវត្ថុតាងនានា ក្នុងករណីចាំបាច់អាចចាត់តាំងអ្នកជំនាញ។

គោលការណ៍នៃការស៊ើបអង្កេតគឺ ត្រូវតែជាការសម្ងាត់។ រាល់ការបំពានលើការសម្ងាត់នៃការស៊ើបអង្កេត គឺជាបទល្មើសដែលត្រូវផ្ដន្ទាទោសតាមច្បាប់ព្រហ្មទណ្ឌជាធរមាន[1]។

### កថាខណ្ឌទី២៖ ចំណាត់ការរបស់អយ្យការ

អង្គការអយ្យការធ្វើការចោទប្រកាន់ពីបទល្មើសព្រហ្មទណ្ឌ និងសន្និដ្ឋានឲ្យតុលាការអនុវត្តច្បាប់។ អង្គការអយ្យការធានារ៉ាប់រងការអនុវត្តនូវសេចក្ដីសម្រេចខាងបទព្រហ្មទណ្ឌ ព្រមទាំងធានាយកចិត្តទុកដាក់លើការផ្សព្វផ្សាយដីកាបង្គាប់ឲ្យចាប់ខ្លួន។

[1] មាត្រា៨៣ ក្រមនីតិវិធីព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជាឆ្នាំ២០០៧

ក្នុងការបំពេញភារកិច្ចរបស់ខ្លួន ចៅក្រមអយ្យការមានសិទ្ធិកេណ្ឌកងកម្លាំងសាធារណៈដោយផ្ទាល់ជាជំនួយ។ ចៅក្រមអយ្យការត្រូវតែមានវត្តមាននៅពេលសវនាការរឿងក្តីព្រហ្មទណ្ឌ[2]។

ចំណាត់ការខាងបទព្រហ្មទណ្ឌមិនអាចចាប់ផ្តើមបានទៀតទេ ឬត្រូវបញ្ឈប់ ប្រសិនបើជនល្មើសទទួលមរណភាព ផុតអាជ្ញាយុកាល ការលើកលែងទោសជាទូទៅ និរាករណ៍នៃច្បាប់ព្រហ្មទណ្ឌ ឬអាជ្ញាអស់ជំនុំជាដើម[3]។

អយ្យការត្រូវធ្វើការត្រួតពិនិត្យទៅលើករណីនៃបទល្មើសមុននឹងធ្វើការចោទប្រកាន់។

**ក. ចំពោះបទល្មើសជាក់ស្តែង**

បទល្មើសជាក់ស្តែង គឺជាបទល្មើសដែលកំពុងប្រព្រឹត្ត ឬបទល្មើសដែលទើបប្រព្រឹត្តរួចភ្លាមៗ។ អាចចាត់ទុកជាបទល្មើសផងដែរ កាលណានៅក្រោយពេលមានបទល្មើសរួចបន្តិចមក៖

- ជនដែលគេសង្ស័យ ត្រូវបានសាធារណៈជនស្រែកដេញប្រដាប់ចាប់ប្រកីង
- បុគ្គលដែលត្រូវគេរកឃើញមានវត្ថុ ឬមានស្លាកស្នាម ឬតម្រុយច្បាស់លាស់ ហើយស៊ីសង្វាក់ផ្សេងទៀតដែលនាំឲ្យគេអាចសន្និដ្ឋានបានថាបុគ្គលនោះបានប្រព្រឹត្ត ឬបានចូលរួមប្រព្រឹត្តបទល្មើស[4]។

ករណីដែលជនល្មើសម្នាក់នៅក្នុងបទល្មើសជាក់ស្តែងត្រូវបានចាប់ខ្លួន ព្រះរាជអាជ្ញាអាចចាប់ផ្តើមបើកការស៊ើបអង្កេតបឋមដោយខ្លួនឯង ក្នុងករណីដែលបទល្មើសនោះជាបទឧក្រិដ្ឋ ឬមជ្ឈិម។ ប្រសិនបើមានការបន្ទាន់ព្រះរាជអាជ្ញាអាចអនុញ្ញាតឲ្យមន្ត្រីនគរបាលយុត្តិធម៌ណាម្នាក់ធ្វើប្រតិបត្តិការលើវិសាលភាពទាំងមូលនៃដែនដីជាតិ។ ចំពោះបទឧក្រិដ្ឋព្រះរាជអាជ្ញាត្រូវសាកសួរជនសង្ស័យតែម្តង កាលណាជននោះត្រូវបាននគរបាលយុត្តិធម៌ ឬអាជ្ញាធរនាំមកតាមដីកាបញ្ជាឲ្យចូលខ្លួន(ដែលអាចចេញដោយព្រះរាជអាជ្ញាដោយខ្លួនឯង) នៅពេលចៅក្រមស៊ើបសួរមិនទាន់បានទទួលបណ្តឹងនៅឡើយ។

ចំពោះបទមជ្ឈិមជាក់ស្តែងដែលមានកម្រិតទោសដាក់ពន្ធនាគារយ៉ាងតិច ១(មួយ)ឆ្នាំ និងយ៉ាងច្រើន ៥(ប្រាំ)ឆ្នាំ ប្រសិនបើសំណុំរឿងមជ្ឈិមនោះមានជនល្មើសតែម្នាក់ចាប់បញ្ជូនមកដោយពុំមានសហចារីដទៃផ្សេងទៀត ព្រះរាជអាជ្ញាអាចបញ្ជូនសំណុំរឿងទៅចៅក្រមជំនុំជម្រះដើម្បីធ្វើការជំនុំជម្រះ។ ចៅក្រមអាចសម្រេចអំពីការឃុំខ្លួនបណ្តោះអាសន្ន ឬសម្រេចអំពីការអនុញ្ញាតឲ្យជនសង្ស័យនៅក្រៅឃុំបណ្តោះអាសន្ន ឬធ្វើការជំនុំជម្រះភ្លាមក៏បានបើយល់ថាសំណុំរឿងមូលគ្រប់គ្រាន់ហើយ[5]។

---

[2] មាត្រា២៧ ក្រមនីតិវិធីព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជាឆ្នាំ២០០៧

[3] មាត្រា៧ ក្រមនីតិវិធីព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជាឆ្នាំ២០០៧

[4] មាត្រា៨៦ ក្រមនីតិវិធីព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជាឆ្នាំ២០០៧

[5] មាត្រា៨៧និង៨៨ ក្រមនីតិវិធីព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជាឆ្នាំ២០០៧

ក្នុងករណី ដែលសំណុំរឿងមជ្ឈិមមានឈ្មោះសហចារីប្រព្រឹត្តបទល្មើសជាក់ស្តែងជាមួយជនដែលចាប់ខ្លួនបានបញ្ជូនទៅឲ្យព្រះរាជអាជ្ញាបានគេចខ្លួនបាត់ដោយមានអត្តសញ្ញាណច្បាស់លាស់ ឬគ្មានអត្តសញ្ញាណនោះទេ ព្រះរាជអាជ្ញាមិនអាចបញ្ជូនសំណុំរឿងទៅចៅក្រមជំនុំជម្រះបានទេ គឺត្រូវធ្វើសេចក្តីសន្និដ្ឋានចោទប្រកាន់បញ្ជូនរឿងឲ្យស៊ើបសួរតាមរយៈ ដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យចៅក្រមស៊ើបសួរ[6] ដើម្បីឲ្យចៅក្រមស៊ើបសួរចាត់ការបន្តតាមនីតិវិធីនៃបទបញ្ញត្តិច្បាប់។

ប្រសិនបើចាប់ជនសង្ស័យមិនបានទេ ទោះបីស្គាល់អត្តសញ្ញាណជននោះ ឬមិនស្គាល់ក្តី ព្រះរាជអាជ្ញាត្រូវអានរបាយការណ៍របស់នគរបាលយុត្តិធម៌ ហើយអាចសួរមន្ត្រីនគរបាលយុត្តិធម៌បានទាក់ទងនឹងចំណុចណាដែលខ្លួនយល់ថាមិនច្បាស់ដើម្បីបញ្ជាក់បន្ថែម ហើយត្រូវកត់ត្រាទុកនៅក្នុងកំណត់ហេតុសួរចម្លើយរបស់មន្ត្រីនគរបាលយុត្តិធម៌ និងវត្ថុតាងដោយត្រូវភ្ជាប់ទៅជាមួយនូវដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរទៅប្រធានតុលាការដើម្បីសុំបើកការស៊ើបអង្កេតលម្អិត។ ព្រះរាជអាជ្ញាត្រូវចុះក្នុងសេចក្តីសន្និដ្ឋានមួយគឺ ដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរ ថាខ្លួនមានវិមតិសង្ស័យលើជនល្មើសដែលបានប្រព្រឹត្តបទល្មើសព្រហ្មទណ្ឌមួយ រួចជូនភ្ជាប់ទៅជាមួយឯកសារសំណុំរឿង និងភស្តុតាងដទៃផ្សេងទៀត ទៅឲ្យចៅក្រមស៊ើបសួរដើម្បីបើកការស៊ើបសួរបន្ត។ ការទទួលវត្ថុតាងត្រូវមានចុះនៅក្នុងទម្រង់មួយដែលគេហៅថា កំណត់ហេតុទទួលវត្ថុតាង[7]។

**ខ. ចំពោះបទល្មើសមិនជាក់ស្តែង**

បទល្មើសទាំងឡាយណាដែលមិនបានបំពេញតាមធាតុផ្សំនៃបទល្មើសជាក់ស្តែងទេ បទល្មើសនោះត្រូវបានចាត់ទុកថាជាបទល្មើសមិនជាក់ស្តែង។ តាមធម្មតានៅក្នុងករណីបទល្មើសមិនជាក់ស្តែងពេលដែលរបាយការណ៍ស្តីអំពីបទល្មើសព្រហ្មទណ្ឌមួយបានទៅដល់ព្រះរាជអាជ្ញា ហើយជនសង្ស័យក៏មិនមានវត្តមាននៅកន្លែងប្រព្រឹត្តបទល្មើសដែរនោះ មានន័យថាការប្រព្រឹត្តបទល្មើសនោះបានសម្រេចរួចទៅហើយ។ ជួនកាលទៀតគេគ្រាន់តែមានភស្តុតាងខ្លះថាជនណាម្នាក់បានប្រព្រឹត្តបទល្មើសដូចជា ជននោះបានលក់គ្រឿងញៀននៅក្នុងផ្ទះជាដើម។ ទំហំនៃភស្តុតាងទាំងនេះមិនអាចឲ្យព្រះរាជអាជ្ញាជឿភ្លាមៗថាជននោះពិតជាបានរកស៊ីលក់គ្រឿងញៀននោះទេ។

ក្នុងករណីនេះបណ្តឹងព្រហ្មទណ្ឌ អាចដាក់ជូនទៅព្រះរាជអាជ្ញាតាមរយៈមន្ត្រីនគរបាលយុត្តិធម៌ ឬតាមរយៈអាជ្ញាធរមានសមត្ថកិច្ចផ្សេងទៀត ឬជនណាម្នាក់ដែលជាជនរងគ្រោះ ឬជាសាច់ញាតិជនរងគ្រោះ ឬអាណាព្យាបាលរបស់ជនរងគ្រោះ។ នៅពេលទទួលពាក្យបណ្តឹងហើយព្រះរាជអាជ្ញាចាប់ផ្តើមធ្វើការស៊ើបអង្កេតបឋមដោយការកោះហៅសាក្សីនានាដែលពាក់ព័ន្ធក្នុង

[6] ឧបសម្ព័ន្ធ

[7] ឧបសម្ព័ន្ធ

រឿងក្តីមានជាអាទិ៍ សាក្សីខាងជនរងគ្រោះ ឬជនសង្ស័យ ដើម្បីសាកសួរឲ្យដឹងថាតើមានមូលដ្ឋានគ្រប់គ្រាន់ដើម្បីចោទប្រកាន់ដែរឬទេ?

ប្រសិនជាបទល្មើសព្រហ្មទណ្ឌមិនជាក់ស្តែងមួយជាប់ទាក់ទងនឹងមន្រ្តីមានក្របខ័ណ្ឌនៃរាជរដ្ឋាភិបាល ព្រះរាជអាជ្ញាមិនអាចចាត់ការបណ្តឹងចោទប្រកាន់តែម្តងបានទេ។ ព្រះរាជអាជ្ញាត្រូវសុំការអនុញ្ញាតយល់ព្រមពីស្ថាប័ន ឬក្រសួងរបស់ជនដែលនឹងត្រូវចោទប្រកាន់នោះធ្វើការជាមុនសិនមុននឹងធ្វើការចោទប្រកាន់ជាផ្លូវការ។ ព្រះរាជអាជ្ញា ត្រូវធ្វើការជម្រាបជូនដំណឹងទៅក្រសួងដែលពាក់ព័ន្ធឲ្យបានដឹងពីដំណឹងនៃការចោទប្រកាន់លើជនដែលជាមន្រ្តីរាជការដែលបានប្រព្រឹត្តបទល្មើសព្រហ្មទណ្ឌនោះ។ ករណីនេះច្បាប់ស្តីពីវិសោធនកម្មស្តីពីសហលក្ខន្តិកៈនៃមន្រ្តីរាជការស៊ីវិលដែលអនុម័តដោយរដ្ឋសភានៅថ្ងៃទី១៧ ខែសីហា ឆ្នាំ១៩៩៩ ត្រង់មាត្រា៥១ បានចែងថា៖ ក្នុងករណីដែលមានមន្រ្តីរាជការណាម្នាក់ ត្រូវជូនដំណឹងអំពីការចោទប្រកាន់នោះទៅប្រធានស្ថាប័នសាមីក្នុងរយៈពេល ៧២(ចិតសិបពីរ) ម៉ោងយ៉ាងយូរ។ បើមានការចាប់ខ្លួន ឬឃាត់ខ្លួន ឬការឃុំខ្លួនជាបណ្តោះអាសន្នលើមន្រ្តីរាជការណាមួយនោះព្រះរាជអាជ្ញា ឬចៅក្រមមានសមត្ថកិច្ចត្រូវរាយការណ៍ជាបន្ទាន់ទៅប្រធានស្ថាប័នសាមី។ ក្នុងករណីដែលបទល្មើសនោះកើតមានក្នុងក្របខ័ណ្ឌនៃការបម្រើការងារសាធារណៈ រដ្ឋត្រូវការពារមន្រ្តីរាជការនោះតាមផ្លូវច្បាប់[8]។

ចំពោះអភ័យឯកសិទ្ធិរបស់សមាជិករដ្ឋសភា ក្នុងករណីបទល្មើសមិនជាក់ស្តែងការចោទប្រកាន់ ការចាប់ខ្លួន ការឃាត់ខ្លួន ការឃុំខ្លួនសមាជិករដ្ឋសភា អាចធ្វើបានលុះត្រាតែមានការយល់ព្រមពីរដ្ឋសភា ឬពីគណៈកម្មាធិការអចិន្រ្តៃយ៍នៃរដ្ឋសភាជាមុនសិន[9]។

ចំពោះអភ័យឯកសិទ្ធិរបស់សមាជិកព្រឹទ្ធសភា ក្នុងករណីប្រព្រឹត្តបទល្មើសមិនជាក់ស្តែងរាល់ការចោទប្រកាន់ ការចាប់ខ្លួន ការឃាត់ខ្លួន ការឃុំខ្លួនសមាជិកព្រឹទ្ធសភាអាចធ្វើទៅបានលុះត្រាតែមានការយល់ព្រមពីព្រឹទ្ធសភា ឬពីគណៈកម្មាធិការអចិន្រ្តៃយ៍ព្រឹទ្ធសភាជាមុនសិន[10]។

## ផ្នែកទី២ ៖ ការចោទប្រកាន់របស់ព្រះរាជអាជ្ញា

### កថាខណ្ឌទី១៖ ជម្រើសនៃការចោទប្រកាន់

ព្រះរាជអាជ្ញា គឺជាគូក្តីដើមជានិច្ចចំពោះបណ្តឹងព្រហ្មទណ្ឌ។ មានន័យថាព្រះរាជអាជ្ញាត្រូវផ្តើមចោទប្រកាន់ខាងបទព្រហ្មទណ្ឌ ហើយទាមទារឲ្យអនុវត្តច្បាប់លើជនត្រូវចោទ។ ការជំនុំជម្រះរឿងក្តីព្រហ្មទណ្ឌត្រូវតែធ្វើឡើងនៅចំពោះមុខវត្តមានរបស់ព្រះរាជអាជ្ញា។ ចំណែកនៅក្នុងរឿងរដ្ឋប្បវេណី

[8] ឧបសម្ព័ន្ធ

[9] មាត្រា៨០ រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជាឆ្នាំ១៩៩៣

[10] មាត្រា១០៤ថ្មី រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជាឆ្នាំ១៩៩៣

វិញ ព្រះរាជអាជ្ញាបំពេញនាទីភាគច្រើនជាគូក្តីរណប និងជាគូក្តីដើមក្នុងករណីនៃរឿងដែលមានផលប៉ះពាល់ដល់របៀបរៀបរយសាធារណៈ ឬដល់ផលប្រយោជន៍របស់អនីតិជន ឬអសមត្ថជន។

ព្រះរាជអាជ្ញាអាចធ្វើបណ្តឹងទៅយុត្តាធិការស៊ើបសួរ ឬយុត្តាធិការជំនុំជម្រះតាមរយៈការចោទប្រកាន់គឺ ការប្តឹងទៅយុត្តាធិការស៊ើបសួរតាមរយៈដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរ និងប្តឹងទៅយុត្តាធិការជំនុំជម្រះតាមរយៈការបញ្ជូនរឿងទៅជំនុំជម្រះផ្ទាល់ ឬតាមកំណត់ហេតុបង្គាប់ឲ្យបង្ហាញខ្លួនភ្លាម[11]។

### ក. ការប្តឹងទៅយុត្តាធិការស៊ើបសួរ

ជាទូទៅគេអាចប្តឹងទៅយុត្តាធិការស៊ើបសួរតាមរយៈដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរ ដែលជាដីកាមួយដែលព្រះរាជអាជ្ញាបញ្ជូនទៅចៅក្រមស៊ើបសួរឲ្យបើកការស៊ើបសួរអំពីរឿងហេតុ ដែលព្រះរាជអាជ្ញាត្រូវកំណត់ដោយមានបញ្ជាក់ពីអត្ថបទច្បាប់ត្រូវអនុវត្តចំពោះបទល្មើសដែលស្ថិតក្រោមការចោទប្រកាន់ផង។ ការចោទប្រកាន់ជាបឋមអាចធ្វើបានក្រោយពីព្រះរាជអាជ្ញាបានទទួលពាក្យបណ្តឹង ជាបទឧក្រិដ្ឋ ឬបទមជ្ឈិម ដើម្បីរកឲ្យឃើញភស្តុតាងសំខាន់ៗដែលអាចនាំទៅរកការចោទប្រកាន់ជនសង្ស័យ។ ក្រោយពីបានព័ត៌មានពីការស៊ើបអង្កេតបឋមរួចមក ព្រះរាជអាជ្ញាអាចស្នើសុំឲ្យចៅក្រមស៊ើបសួរធ្វើការស៊ើបសួររកភស្តុតាងកំណត់អំពីបទល្មើស ភស្តុតាងដាក់បន្ទុក និងភស្តុតាងដោះបន្ទុកតាមរយៈដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរ(លិខិតទាក់ទងរវាងចៅក្រមស៊ើបសួរជាមួយព្រះរាជអាជ្ញា) បើយល់ឃើញថារឿងនេះមានលក្ខណៈស្មុគស្មាញ។ ប៉ុន្តែក្នុងករណីបទមជ្ឈិម ការស៊ើបសួរមានលក្ខណៈមិនដាច់ខាតទេគឺ អាស្រ័យទៅលើស្ថានភាពនៃសំណុំរឿងតែប៉ុណ្ណោះ។

តាមធម្មតាព្រះរាជអាជ្ញា ក៏មានភារកិច្ចស្វែងរកជនដែលប្រព្រឹត្តបទលហុដែរ ប្រសិនបើនគរបាលយុត្តិធម៌បញ្ជូនឲ្យព្រះរាជអាជ្ញានូវសេចក្តីសន្និដ្ឋានរបស់ខ្លួន ដោយកោះហៅជនជាប់ចោទឲ្យចូលខ្លួនទៅមុខតុលាការជំនុំជម្រះដោយផ្ទាល់អំពីកម្រិតទណ្ឌកម្មដែលត្រូវផ្តន្ទាទោសជនជាប់ចោទនោះបានតាមរយៈដីកាកោះហៅបញ្ជូនទៅជំនុំជម្រះផ្ទាល់[12]។

ចំណែកឯក្នុងករណីបទឧក្រិដ្ឋវិញ ព្រះរាជអាជ្ញាត្រូវតែបើកការស៊ើបសួរតាមរយៈដីកាបញ្ជូនរឿងឲ្យស៊ើបសួរដែលត្រូវប្តឹងទៅចៅក្រមស៊ើបសួរ។ ការស៊ើបសួរអាចបើកប្រឆាំងលើបុគ្គលម្នាក់ ឬច្រើននាក់ដោយមានការចង្អុលបង្ហាញប្រាប់ឈ្មោះ ឬប្រឆាំងទៅលើអញ្ញាត្រជន ហើយដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរនោះ ត្រូវមានសេចក្តីសង្ខេបនៃអង្គហេតុស្តីពីការកំណត់ឈ្មោះបទល្មើស បង្ហាញអត្ថបទច្បាប់ដែលបានកំណត់ និងបង្ក្រាបបទល្មើសរួមទាំងឈ្មោះបុគ្គល ដែលត្រូវរងការ

[11] មាត្រា៤៣ដល់មាត្រា៤៨ ក្រមនីតិវិធីព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជាឆ្នាំ២០០៧

[12] មាត្រា៤៥.៤៦និងមាត្រា៤៩ ក្រមនីតិវិធីព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជាឆ្នាំ២០០៧

ស៊ើបសួរ (ប្រសិនបើអាចកំណត់បាន)។ ដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរត្រូវតែមានចុះកាលបរិច្ឆេទ និងហត្ថលេខា។ ទម្រង់ការនេះមានលក្ខណៈដាច់ខាតត្រូវតែគោរព បើពុំដូច្នេះទេដីកាបញ្ជូនរឿងឲ្យស៊ើបសួរនេះត្រូវទុកជាមោឃៈ[13]។

ករណីបទឧក្រិដ្ឋ ឬបទមជ្ឈិមមិនជាក់ស្តែងវិញ ព្រះរាជអាជ្ញាត្រូវស្នើសុំឲ្យចៅក្រមស៊ើបសួរបើកការស៊ើបសួរសិនមុននឹងធ្វើការចោទប្រកាន់ជាស្ថាពរ ទោះបីទោសដែលត្រូវផ្តន្ទាទោសចំពោះបទល្មើសនោះមានរយៈពេលប៉ុន្មានក៏ដោយ។

### ខ. ការបញ្ជូនទៅយុត្តាធិការជំនុំជម្រះ

ក្នុងដំណាក់កាលនៃនីតិវិធីនេះ បើព្រះរាជអាជ្ញាយល់ឃើញថាសំណុំរឿងអាចបញ្ជូនទៅតុលាការជំនុំជម្រះដោយពុំចាំបាច់មានការស្រាវជ្រាវផ្សេងទៀតទេ។ ស្ថានភាពនៃសំណុំរឿងនេះព្រះរាជអាជ្ញាអាចសន្មត់ជាដំបូងបានថា បានសង្ស័យទៅលើបុគ្គលណាម្នាក់ ឬច្រើននាក់ដែលបានកំណត់អត្តសញ្ញាណ ហើយដែលបានបង្ក្រាបពីបទល្មើសមួយ ឬច្រើនដែលបទល្មើសនោះអាចជាបទមជ្ឈិម ឬបទលហុ។

ក្នុងករណីដែលព្រះរាជអាជ្ញាសម្រេចអនុវត្តប្រភេទចំណាត់ការផ្ទាល់នៃរឿងព្រហ្មទណ្ឌក្រោយពេលបញ្ចប់ការស្រាវជ្រាវដែលជាទូទៅគឺ នៅពេលដែលថិរវេលាឃាត់ខ្លួន ឬមិនមានការឃាត់ខ្លួន ព្រះរាជអាជ្ញាអាចសម្រេចឲ្យបុគ្គលដែលពាក់ព័ន្ធម្នាក់ ឬច្រើននាក់មកបង្ហាញខ្លួននៅចំពោះមុខដើម្បីធ្វើការចោទប្រកាន់ តាមរយៈការបង្គាប់ឲ្យចូលបង្ហាញខ្លួនភ្លាម ឬបញ្ជូនទៅជំនុំជម្រះផ្ទាល់។

#### ខ.១. ការបង្ហាញខ្លួនភ្លាម

តាមរយៈនៃការបង្ហាញខ្លួនភ្លាមនេះព្រះរាជអាជ្ញអាចបង្គាប់ឲ្យនាំខ្លួនជនជាប់ចោទចូលមកបង្ហាញខ្លួនភ្លាម នៅចំពោះមុខតុលាការនៃសាលាដំបូង ប្រសិនបើមានលក្ខខណ្ឌគ្រប់គ្រាន់ដូចជាបទល្មើសជាបទល្មើសមជ្ឈិមជាក់ស្តែង ដែលត្រូវផ្តន្ទាទោសដាក់ពន្ធធនាគារយ៉ាងតិច ១(មួយ)ឆ្នាំ និងយ៉ាងច្រើន ៥(ប្រាំ)ឆ្នាំ ឬជនជាប់ចោទជានីតិជន និងរឿងក្តីដែលមានលក្ខណៈគ្រប់គ្រាន់ល្មមអាចជំនុំជម្រះបាន[14]។ ប៉ុន្តែបទល្មើសមជ្ឈិមដែលប្រព្រឹត្តដោយជនជាប់ចោទជាអនីតិជនវិញគឺ មិនអាចចោទប្រកាន់តាមបែបនៃការបង្ហាញខ្លួននេះបានទេ។

ពេលបញ្ចប់ការឃាត់ខ្លួនបុគ្គលដែលឃាត់ខ្លួនត្រូវបញ្ជូនមកដោយមន្ត្រីនគរបាលយុត្តិធម៌ដើម្បីឲ្យចូលបង្ហាញខ្លួននៅចំពោះមុខព្រះរាជអាជ្ញា។ បន្ទាប់ពីការសាកសួរពីអត្តសញ្ញាណរបស់ជនត្រូវចោទហើយ ព្រះរាជអាជ្ញាត្រូវឲ្យដំណឹងទៅជននោះអំពីរឿងរ៉ាវដែលត្រូវចោទប្រកាន់ស្តីពីអត្ថបទ

---

[13] មាត្រា៤៤ ក្រមនីតិវិធីព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជាឆ្នាំ២០០៧

[14] មាត្រា៤៧ ក្រមនីតិវិធីព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជាឆ្នាំ២០០៧

ច្បាប់ដែលបានកំណត់ និងការបង្ក្រាបបទល្មើសដោយប្រាប់ពីសិទ្ធិទទួលបានជំនួយពីមេធាវីតាមការជ្រើសរើសរបស់ខ្លួន ឬតាមរយៈការចាត់តាំងមេធាវី។ ព្រះរាជអាជ្ញាអាចត្រូវបញ្ជូនជនជាប់ចោទ និងសំណុំរឿងទៅតុលាការដើម្បីជំនុំជម្រះនៅពេលនោះភ្លាមៗ តាមរយៈកំណត់ហេតុស្តីពីការបង្គាប់ឲ្យចូលបង្ហាញខ្លួនភ្លាម។

### ខ.២. ដីកាកោះហៅបញ្ជូនទៅជំនុំជម្រះផ្ទាល់

ដីកាកោះហៅបញ្ជូនរឿងទៅជំនុំជម្រះផ្ទាល់ គឺជាបញ្ជាឲ្យជនជាប់ចោទចូលទៅបង្ហាញខ្លួននៅចំពោះមុខសាលាដំបូង។ ក្នុងដីកានោះរួមមាន អត្តសញ្ញាណនៃជនជាប់ចោទ សេចក្តីសង្ខេបនៃអង្គហេតុ ឈ្មោះបទល្មើស អត្ថបទច្បាប់ដែលកំណត់ និងបង្ក្រាបបទល្មើសដោយចង្អុលបង្ហាញប្រាប់ទៅតុលាការ ព្រមទាំងទីកន្លែង កាលបរិច្ឆេទ និងម៉ោងសវនាការ។ ដីកានេះត្រូវបញ្ជាក់ថាជនជាប់ចោទអាចពឹងមេធាវីអមខ្លួនបាន[15]។ ដីកាកោះអាចត្រូវប្រគល់ឲ្យជនជាប់ចោទដោយផ្ទាល់ដៃដោយព្រះរាជអាជ្ញា ឬអាជ្ញាសាលាតែត្រូវបង្ហាញខ្លួនក្នុងរយៈពេល១៥(ដប់ប្រាំ)ថ្ងៃបន្ទាប់ពីបានទទួលដីកានេះ ប្រសិនបើជនជាប់ចោទរស់នៅក្នុងដែនដីនៃតុលាការជាន់ដំបូងនោះ[16] ។

ប្រសិនជាព្រះរាជអាជ្ញានៅតែសង្ស័យមិនច្បាស់លើចំណុចខ្លះនៅក្នុងបណ្តឹងនោះ ព្រះរាជអាជ្ញាអាចធ្វើការស៊ើបអង្កេតដោយខ្លួនឯង ឬបង្គាប់ឲ្យនគរបាលយុត្តិធម៌ស៊ើបអង្កេតជំនួសខ្លួនបានមុននឹងបញ្ជូនទៅតុលាការ។

ប្រសិនបើមិនមានហេតុផល ឬភស្តុតាងល្មមនឹងជឿបានថា បទល្មើសព្រហ្មទណ្ឌនោះត្រូវបានប្រព្រឹត្តមែន នោះព្រះរាជអាជ្ញាត្រូវចេញដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួររួមជាមួយនឹងឯកសារដទៃទៀតទៅឲ្យប្រធានតុលាការដើម្បីធ្វើការស៊ើបសួរតទៅទៀត។ បន្ទាប់មក ប្រធានតុលាការចាត់តាំងចៅក្រមម្នាក់ដែលគេហៅថា ចៅក្រមស៊ើបសួរ ឲ្យធ្វើការបើកការស៊ើបសួរ។

ចំណែកឯបទល្មើសលហុវិញ ព្រះរាជអាជ្ញាត្រូវតែបញ្ជូនទៅជម្រះតាមរយៈ ដីកាកោះហៅបញ្ជូនទៅជំនុំជម្រះផ្ទាល់។

## កថាខណ្ឌទី២៖ ជម្រើសផ្សេងក្រៅពីការចោទប្រកាន់

គ្រប់បណ្តឹងនៃអំពើដែលព្រះរាជអាជ្ញាទទួលទាំងអស់ មិនសុទ្ធតែត្រូវបានចោទប្រកាន់ធ្វើបណ្តឹងអាជ្ញាទាំងអស់នោះទេ ពោលគឺអំពើខ្លះអាចចាត់វិធានការផ្សេងពីការចោទប្រកាន់បាន ដែលក្នុងនោះរួមមាន ការតម្កល់រឿងទុកឥតចាត់ការ និងការបញ្ចប់រឿងដោយសារមូលហេតុផ្សេងពីការរលត់នៃបណ្តឹងអាជ្ញា។

---

[15] មាត្រា៤៦ ក្រមនីតិវិធីព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជាឆ្នាំ២០០៧

[16] មាត្រា៤៦៦ ក្រមនីតិវិធីព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជាឆ្នាំ២០០៧

ការអនុវត្តជម្រើសទាំងអស់នេះ ព្រះរាជអាជ្ញាជាអ្នកវាយតម្លៃអំពីអំពើល្មើសទាំងនោះ ឬដោយសារមានអត្ថបទផ្សេងទៀតអនុញ្ញាតឲ្យបញ្ចប់នីតិវិធីដោយការព្រមព្រៀងណាមួយ។

### ក. ការតម្កល់រឿងទុកឥតចាត់ការ

ជម្រើសមិនចោទប្រកាន់ស្តែងចេញតាមរយៈ សេចក្តីសម្រេចតម្កល់រឿងទុកឥតចាត់ការដែលផ្អែកលើការវាយតម្លៃរបស់ព្រះរាជអាជ្ញាតែមួយគត់។ យើងសង្កេតឃើញថា រដ្ឋមន្ត្រីក្រសួងយុត្តិធម៌អាចធ្វើអធិបញ្ញាឲ្យធ្វើការចោទប្រកាន់ តែមិនអាចបញ្ជាឲ្យតម្កល់រឿងទុកឥតចាត់ការនូវរឿងណាមួយបានឡើយ ហើយមូលហេតុនៃការតម្កល់រឿងទុកឥតចាត់ការមានច្រើន និងមិនបានកំណត់ដោយច្បាប់ទេ។

ការតម្កល់រឿងទុកឥតចាត់ការអាចមានមូលហេតុមកពី អំពើប្រព្រឹត្តនោះមិនមានធាតុផ្សំគ្រប់គ្រាន់ជាបទល្មើស ឬបទល្មើសដែលមានកម្រិត និងចរិតគ្រោះថ្នាក់តូចតាចជាដើម ហើយការស្រាវជ្រាវបន្ថែមដែលមើលទៅហាក់ដូចជាគ្មានប្រយោជន៍ និងគ្មានប្រសិទ្ធិភាព។

ការតម្កល់រឿងទុកឥតចាត់ការអាចធ្វើឡើងទោះបីបទល្មើស ឬអ្នកប្រព្រឹត្តបទល្មើសត្រូវបានគេស្គាល់មុខ ប៉ុន្តែព្រះរាជអាជ្ញាយល់ថាការតម្កល់រឿងទុកឥតចាត់ការនេះត្រូវតាមកាលៈទេសៈព្រោះព្យសនកម្មដែលកើតមានដោយសារបទល្មើសតិចតួច ឬគ្មានភាពរឹករវដល់សណ្តាប់ធ្នាប់សាធារណៈដែលមានលក្ខណៈធ្ងន់ធ្ងរ ឬដោយសារបុគ្គលិកលក្ខណៈរបស់ចារី ឬអត្តចរិតរបស់ជនរងគ្រោះ។ល។

ការតម្កល់រឿងទុកឥតចាត់ការធ្វើឡើងដោយសេចក្តីសម្រេចដែលមានសំអាងហេតុ និងសំអាងច្បាប់ដោយព្រះរាជអាជ្ញា និងត្រូវឲ្យដំណឹងយ៉ាងខ្លីបំផុតដល់អ្នកប្តឹង ហើយយ៉ាងយូរបំផុតត្រឹមរយៈពេល២(ពីរ)ខែគិតពីថ្ងៃចុះពាក្យបណ្តឹងក្នុងបញ្ជី។ សេចក្តីសម្រេចតម្កល់រឿងទុកឥតចាត់ការគឺ អាចធ្វើការតវ៉ាក្នុងកំឡុងពេល២(ពីរ)ខែ គិតពីថ្ងៃទទួលដំណឹងអំពីសេចក្តីសម្រេចនោះ។ ការតវ៉ាធ្វើឡើងតាមរយៈបណ្តឹងសាមញ្ញនៅអង្គការអយ្យការដែលពាក់ព័ន្ធ បន្ទាប់មកសំណុំរឿងត្រូវបញ្ជូនភ្លាមទៅអគ្គព្រះរាជអាជ្ញាអមសាលាឧទ្ធរណ៍ ដោយតំណាងអយ្យការអមសាលាដំបូង។ ដីកាសម្រេចតម្កល់រឿងទុកឥតចាត់ការនេះ ពុំមានអាជ្ញាអស់ជំនុំទេ បើក្រោយមកព្រះរាជអាជ្ញារកឃើញបន្ទុកគ្រប់គ្រាន់នោះ ព្រះរាជអាជ្ញាអាចចោទប្រកាន់បាន។

ការតម្កល់រឿងទុកឥតចាត់ការក៏អាចត្រូវបានចោទប្រកាន់វិញផងដែរ ក្នុងករណីដែលអគ្គព្រះរាជអាជ្ញាអមសាលាឧទ្ធរណ៍យល់ឃើញថា ការតវ៉ានេះមានមូលហេតុត្រឹមត្រូវដោយចេញអធិបញ្ញាដល់ព្រះរាជអាជ្ញាអមសាលាដំបូងឲ្យធ្វើការចោទប្រកាន់។ អធិបញ្ញារបស់អគ្គព្រះរាជអាជ្ញាត្រូវធ្វើការណែនាំជាលាយលក្ខណ៍អក្សរ ប៉ុន្តែប្រសិនបើការតវ៉ានេះមិនមានមូលហេតុត្រឹមត្រូវ អគ្គព្រះរាជអាជ្ញាអមសាលាឧទ្ធរណ៍អាចតម្កល់សេចក្តីសម្រេចរបស់ព្រះរាជអាជ្ញាអមសាលាដំបូង

ចាត់ទុកជាបានការហើយ អគ្គព្រះរាជអាជ្ញាអមសាលាឧទ្ធរណ៍ត្រូវឲ្យដំណឹងអំពីសេចក្ដីសម្រេចនេះដល់អ្នកប្ដឹងតវ៉ា។

### ខ. ករណីមិនគួរចោទប្រកាន់

ក្រៅពីជម្រើសនៃការចោទប្រកាន់ និងការតម្កល់រឿងទុកឥតចាត់ការ សំណុំរឿងអាចត្រូវសម្របសម្រួលជាមួយរដ្ឋ ឬបង់ប្រាក់ពិន័យសរុប ឬការដកពាក្យបណ្ដឹងដោយជនរងគ្រោះក្នុងករណីដែលពាក្យបណ្ដឹងនេះជាលក្ខខណ្ឌចាំបាច់នៃការចោទប្រកាន់ជាបទល្មើសព្រហ្មទណ្ឌ។ ក្នុងករណីនេះ អាចអនុវត្តបានលុះត្រាតែមានចែងដោយជាក់លាក់នៅក្នុងច្បាប់ដោយឡែក។

ការសម្របសម្រួលជាមួយរដ្ឋអាចធ្វើបានគ្រប់ពេលវេលា ប្រសិនបើមានចែងនៅក្នុងច្បាប់ដោយឡែក ហើយការសម្របសម្រួលនេះអាចធ្វើទៅបាន លុះត្រាតែអំពើនោះមិនបានធ្វើឲ្យប៉ះពាល់ធ្ងន់ធ្ងរដល់សណ្ដាប់ធ្នាប់សាធារណៈ ហើយជនដែលប្រព្រឹត្តបានទទួលស្គាល់នូវកំហុស ហើយមានការសន្យាណាមួយជាក់លាក់។ ការសម្របសម្រួលជាមួយរដ្ឋនេះយើងសង្កេតឃើញថាអាចមានការព្រមានជាលាយលក្ខណ៍អក្សរជាដើម។

ការដកពាក្យបណ្ដឹងដោយជនរងគ្រោះអាចធ្វើទៅបានចំពោះបទល្មើសមួយចំនួន ប្រសិនបើមានមូលហេតុនៃបណ្ដឹង គឺជាលក្ខខណ្ឌចាំបាច់នៃការចោទប្រកាន់ពីបទល្មើសព្រហ្មទណ្ឌ។ ក្នុងលក្ខខណ្ឌនេះ យើងឃើញមានបទល្មើសមួយចំនួនដូចជា បទរំលោភសេពសន្ថវៈ បទអំពើហិង្សាក្នុងគ្រួសារ ជាដើម។ ក្នុងបទរំលោភសេពសន្ថវៈ ប្រសិនបើជនរងគ្រោះដកពាក្យបណ្ដឹងដោយអះអាងថាខ្លួនបានយល់ព្រមជាមួយជនរងគ្រោះ នោះព្រះរាជអាជ្ញាក៏មិនអាចធ្វើការចោទប្រកាន់ទៀតបានដែរ។ រីឯអំពើហិង្សាក្នុងគ្រួសារវិញ ប្រសិនបើសហព័ទ្ធណាមួយជាជនរងគ្រោះបានដកពាក្យបណ្ដឹងចំពោះសហព័ទ្ធរបស់ខ្លួននោះ ព្រះរាជអាជ្ញាក៏មិនអាចធ្វើការចោទប្រកាន់បន្តទៀតបានដែរ។ ចំពោះបទទ្វេរពន្ធភាពក៏ដូចគ្នាដែរ ប្រសិនបើសហព័ទ្ធណាមួយដកពាក្យបណ្ដឹងនាំឲ្យរឿងនោះត្រូវបានបញ្ចប់ដូចគ្នាដែរ។

មូលហេតុដែលធ្វើឲ្យរំលត់បណ្ដឹងអាជ្ញាមានដូចជា មរណៈភាពនៃជនល្មើស ការផុតអាជ្ញាយុកាល ការលើកលែងទោសជាទូទៅ និរាករណ៍នៃច្បាប់ព្រហ្មទណ្ឌ និងអាជ្ញាអស់ជំនុំ[17]។

ជាចុងក្រោយយើងសង្កេតឃើញថា បទល្មើសមួយចំនួនអាចបញ្ចប់បានដោយមិនចាំបាច់ធ្វើបណ្ដឹងអាជ្ញា គឺគ្រាន់តែបង់ប្រាក់ពិន័យសរុប ឬបង់ប្រាក់ពិន័យសម្របសម្រួលជាការបញ្ចប់រឿងជាក់ស្ដែងដូចជា បទល្មើសចរាចរណ៍ជាដើម។

[17] មាត្រា៧ ក្រមនីតិវិធីព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជាឆ្នាំ២០០៧

# ជំពូកទី២
# នីតិវិធីនៃការស៊ើបសួរ

## ផ្នែកទី១៖ ចៅក្រមស៊ើបសួរ

នៅក្នុងប្រព័ន្ធច្បាប់ព្រហ្មទណ្ឌរបស់ប្រទេសកម្ពុជា ចៅក្រមស៊ើបសួរដើរតួនាទីយ៉ាងសំខាន់ក្នុងការស្វែងរកការពិត។ តួនាទីយ៉ាងសំខាន់របស់ចៅក្រមស៊ើបសួរនោះគឺ ការស្រាវជ្រាវស្វែងរកភស្តុតាង ការកំណត់បទល្មើស ការស្វែងរកភស្តុតាងដាក់បន្ទុក និងដោះបន្ទុក។

### កថាខណ្ឌទី១៖ ការរៀបចំចៅក្រមស៊ើបសួរ

ចៅក្រមស៊ើបសួរត្រូវចាត់តាំងដោយប្រធានតុលាការ។ កាលណាចៅក្រមស៊ើបសួរណាម្នាក់ពុំអាចបំពេញមុខងាររបស់ខ្លួនបានដោយការឈប់សម្រាកដោយសារជំងឺ ឬដោយមានមូលហេតុផ្សេងទៀតនោះ ចៅក្រមស៊ើបសួរផ្សេងទៀតនៃតុលាការដដែលត្រូវបានចាត់តាំងជាបណ្ដោះអាសន្នដោយប្រធានតុលាការ ដើម្បីបំពេញមុខងារស៊ើបសួរបន្ត។ ប្រធានតុលាការអាចចេញដីកាចាត់តាំងមួយដែលពុំបើកផ្លូវតវ៉ាឡើយ[18]។

### កថាខណ្ឌទី២៖ ការដកហូតសំណុំរឿងពីចៅក្រមស៊ើបសួរ

ការដកហូតសំណុំរឿងពីចៅក្រមស៊ើបសួរ ដើម្បីប្រគល់ជូនចៅក្រមស៊ើបសួរម្នាក់ទៀតអាចស្នើទៅប្រធានតុលាការ ដើម្បីជាប្រយោជន៍នៃរដ្ឋបាលដ៏ល្អរបស់ស្ថាប័នយុត្តិធម៌។ ការស្នើនេះអាចធ្វើឡើងដោយពាក្យសុំដែលមានសំអាងហេតុរបស់ព្រះរាជអាជ្ញា ដែលធ្វើឡើងដោយការផ្ដើមគំនិតផ្ទាល់ខ្លួន ឬតាមរយៈពាក្យបណ្ដឹងរបស់ភាគី[19]។

## ផ្នែកទី២៖ដំណើរការស៊ើបសួរ និងបញ្ជូនលទ្ធផលនៃកិច្ចស៊ើបសួរទៅព្រះរាជអាជ្ញា

### កថាខណ្ឌទី១៖ ការបំពេញកិច្ចរបស់ចៅក្រមស៊ើបសួរ

ចៅក្រមស៊ើបសួរមានតួនាទីយ៉ាងសំខាន់ក្នុងវិស័យយុត្តាធិការ ហើយក្នុងនាមជាចៅក្រមដែលស្វែងរកយុត្តិធម៌ជូនភាគី រាល់គ្រប់កិច្ចដែលអនុវត្តដោយចៅក្រមស៊ើបសួរត្រូវតែមានចែងនៅក្នុងក្រមដែលមិនសំដៅថាចៅក្រមស៊ើបសួរត្រូវតែអនុវត្តគ្រប់កិច្ចដែលមានចែងនៅក្នុងក្រមនោះទេ ពោលគឺចៅក្រមស៊ើបសួរត្រូវអនុវត្តកិច្ចទាំងឡាយណា ដែលចាំបាច់សម្រាប់សម្ដែងឲ្យឃើញការពិត ។

ចៅក្រមស៊ើបសួរទទួលបន្ទុកស៊ើបសួរតាមរយៈដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួររបស់អយ្យការ។ លើសពីនេះទៅទៀតចៅក្រមស៊ើបសួរជាអ្នកទទួលបន្ទុកស៊ើបសួរនៅពេលដែលមាន

[18] មាត្រា៥១ ក្រមនីតិវិធីព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជាឆ្នាំ២០០៧

[19] មាត្រា៥២ ក្រមនីតិវិធីព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជាឆ្នាំ២០០៧

បណ្ដឹងដោយមានការតាំងខ្លួនជាដើមបណ្ដឹងរដ្ឋប្បវេណីរបស់ជនរងគ្រោះ ដែលបានប្ដឹងមកចៅក្រមស៊ើបសួរដោយផ្ទាល់។ នៅពេលបំពេញកិច្ចស៊ើបសួរចៅក្រមស៊ើបសួរអាចស្វែងរកភស្តុតាងតាមរយៈការចូលរួមរបស់ជនត្រូវចោទ សាក្សី ជនរងគ្រោះ ប្រមូលយកវត្ថុតាង ឯកសារ ធ្វើការសួរចម្លើយ សម្ភាស និងធ្វើកោសលវិច័យ ដើម្បីវិភាគរកភស្តុតាង ធ្វើការឆែកឆេរលំនៅឋាន រឹបអូសវត្ថុផ្សេងដែលអាចជួយសម្រួលក្នុងការបញ្ជាក់ភស្តុតាង។ល។ ចៅក្រមស៊ើបសួរក៏អាចចេញដីកាបង្គាប់ឲ្យនាំខ្លួនសាក្សីមកតុលាការបានបើសាក្សីដែលត្រូវបានកោះហៅហើយនោះ នៅរឹងទទឹងមិនព្រមចូលមកបំភ្លឺ។

នៅពេលដែលជនត្រូវចោទចូលខ្លួននៅចំពោះមុខនោះ ចៅក្រមស៊ើបសួរត្រូវប្រាប់ជននោះអំពីបទចោទប្រកាន់មកលើខ្លួន ប្រាប់ពីសិទ្ធិមិនទាន់ឆ្លើយនៅពេលមិនទាន់មានមេធាវីមកការពារខ្លួន និងប្រាប់ពីសិទ្ធិជ្រើសរើសរកមេធាវីដោយខ្លួនឯង ឬបើមិនមានលទ្ធភាពទេជននោះមានសិទ្ធិឲ្យតុលាការចាត់តាំងមេធាវីឲ្យមកការពារខ្លួនបាន។ ការសាកសួរចម្លើយជនត្រូវចោទត្រូវតែធ្វើនៅចំពោះមុខមេធាវី ប្រសិនបើជនជាប់ចោទមានមេធាវី។ វត្តមានរបស់មេធាវីត្រូវតែមានជាចាំបាច់ក្នុងករណីជនត្រូវចោទជាអនីតិជន។

ជាការសំខាន់ការសួរចម្លើយត្រូវប្រើបច្ចេកទេស ឬសិល្បៈផ្ទាល់ខ្លួនដើម្បីសួរយកចម្លើយ។ នៅពេលសួរចម្លើយសាក្សីមិនចាំបាច់មានវត្តមានមេធាវីនៅទីនោះទេ។ តែទោះបីជាយ៉ាងណាក្តីមេធាវីការពារក្តីមានសិទ្ធិមើលសំណុំរឿង ឬពិនិត្យមើលចម្លើយទាំងឡាយដែលចៅក្រមស៊ើបសួរប្រមូលបាន។

### គ. ការស្វែងរកអង្គហេតុពិត

ដើម្បីឲ្យការស៊ើបសួរមានលក្ខណៈយុត្តិធម៌ និងតម្លាភាព ចៅក្រមស៊ើបសួរត្រូវស្វែងរកអង្គហេតុពិតនៃអំពើរបស់បុគ្គលដែលបានប្រព្រឹត្ត។

មុននឹងធ្វើការចោទប្រកាន់ចៅក្រមស៊ើបសួរត្រូវស្វែងរកថា អំពើដែលបានប្រព្រឹត្តនោះជាបទល្មើស ឬមិនមែនជាបទល្មើស។

#### គ.១. ករណីគ្មានបទល្មើស

ប្រសិនបើ អំពើដែលបានប្រព្រឹត្តឡើងដោយពុំមានធាតុផ្សំនៃបទល្មើសគ្រប់គ្រាន់ទេនោះគេពុំអាចចោទប្រកាន់ថាជាបទល្មើសបានឡើយ។ ការចាត់ទុកថាអំពើប្រព្រឹត្តជាបទល្មើសបានលុះត្រាតែអំពើនោះបានបំពេញនូវធាតុផ្សំទាំងបី គឺធាតុនីត្យានុកូល ធាតុសត្យានុម័ត និងធាតុអត្តនោម័ត។

#### គ.២. ករណីមានបទល្មើស

ដើម្បីធ្វើការចោទប្រកាន់អំពើណាមួយជាបទល្មើស គឺត្រូវតែបំពេញនូវធាតុផ្សំទាំងបីដែលមានដូចខាងក្រោម៖

❖ ធាតុនីត្យានុកូល ឬធាតុច្បាប់ មានន័យថានឹងអាចចោទប្រកាន់ទៅលើជនណាម្នាក់ថាជាជនប្រព្រឹត្តបទល្មើស ឬអាចដាក់ទោសទៅលើជនណាម្នាក់បាន លុះត្រាតែជននោះបានប្រព្រឹត្តអំពើផ្ទុយនឹងបញ្ញត្តិច្បាប់ព្រហ្មទណ្ឌដែលកំពុងនៅជាធរមាន។

❖ ធាតុសត្យានុម័ត សំដៅលើអំពើប្រព្រឹត្តទោះបីដោយសកម្មក្តី ឬអសកម្មក្តី ដែលអំពើនោះបានបណ្តាលឲ្យមានផលប៉ះពាល់ដល់សេរីភាព បូរណភាពបុគ្គល ទ្រព្យសម្បត្តិសាធារណៈ ឬឯកជនជាដើម។ បទល្មើសសកម្ម សំដៅលើអំពើប្រព្រឹត្តទាំងឡាយណាដែលអាចបង្ហាញឲ្យឃើញតាមរយៈសកម្មភាពរបស់ជនល្មើសដែលផ្ទុយនឹងច្បាប់ព្រហ្មទណ្ឌ។ ឧទាហរណ៍៖ បទឃាតកម្ម បទរំលោភសេពសន្ថវៈ បទហិង្សាដោយចេតនា ជាដើម។ ចំណែកឯបទល្មើសអកម្មវិញ គឺជាបទល្មើសដែលជនល្មើសមិនព្រមបំពេញនូវកាតព្វកិច្ចអ្វីមួយទៅតាមច្បាប់ព្រហ្មទណ្ឌតម្រូវ។ ឧទាហរណ៍៖ បទមិនប្តឹងបរិហារពីបទឧក្រិដ្ឋ (មាត្រា៥២៩)។

❖ ធាតុអត្តនោម័ត គឺសំដៅលើស្ថានភាពផ្លូវចិត្តរបស់ជនដែលបានប្រព្រឹត្តបទល្មើសណាមួយ។ ជាគោលការណ៍ច្បាប់ព្រហ្មទណ្ឌបានចែងថា ដើម្បីអាចផ្តន្ទាទោសទៅលើជនដែលបានប្រព្រឹត្តអំពើណាមួយ លុះត្រាណាតែអំពើដែលជននោះបានសម្តែងចេញនូវចេតនាក្នុងការប្រព្រឹត្ត ឬមានចេតនាទុច្ចរិត។

### ខ. ការស្វែងរកភស្តុតាង

នៅក្នុងប្រទេសកម្ពុជា គេមិនទាន់ឃើញមានវិធានស្តីអំពីការប្រើប្រាស់ភស្តុតាង និងការរកភស្តុតាងទេ។ ការរក និងការបង្ហាញភស្តុតាងអាចធ្វើបានតាមគ្រប់វិធី ប៉ុន្តែចៅក្រមត្រូវប្រើឆន្ទានុសិទ្ធិរបស់ខ្លួនដើម្បីសម្របសម្រួលក្នុងរឿងនេះ។ ភស្តុតាងអាចមាន២ (ពីរ)គឺ៖

#### ខ.១. ភស្តុតាងដាក់បន្ទុក

ភស្តុតាងដាក់បន្ទុក ជាភស្តុតាងដែលគាំទ្រចំណុចនៃបណ្តឹង ហើយដែលធ្វើឲ្យមានប្រយោជន៍ដល់បណ្តឹង ពោលគឺបានបង្ហាញថា ជនត្រូវចោទពិតជាបានប្រព្រឹត្តបទល្មើសពិតប្រាកដមែន ហើយភស្តុតាងនេះអាចធ្វើឲ្យមានគុណប្រយោជន៍ដល់ដើមបណ្តឹងរដ្ឋប្បវេណី និងបណ្តឹងអាជ្ញា ។

#### ខ.២. ភស្តុតាងដោះបន្ទុក

ភស្តុតាងដោះបន្ទុកវិញ ជាភស្តុតាងខាងជនជាប់ចោទដែលបង្ហាញថាជនល្មើសមិនបានប្រព្រឹត្តបទល្មើស ឬពុំមានភស្តុតាងគ្រប់គ្រាន់បញ្ជាក់ថាបានប្រព្រឹត្តបទល្មើស ដើម្បីបានឈ្នះជាប្រយោជន៍ដល់ខ្លួន ហើយភស្តុតាងនេះអាចគាំទ្រដល់ការដោះសារពីការចោទប្រកាន់របស់គេ ។

## គ. វិធានការនិរន្តរាយ

### គ.១.ការសម្រេចឲ្យឃុំខ្លួន ឬការអនុញ្ញាតឲ្យនៅក្រៅឃុំជាបណ្ដោះអាសន្ន

អំពីស្ថានភាពរបស់ជនត្រូវចោទវិញ ចៅក្រមស៊ើបសួរអាចសម្រេចថាត្រូវឃុំខ្លួនបណ្ដោះអាសន្ន ឬអនុញ្ញាតឲ្យនៅក្រៅឃុំបណ្ដោះអាសន្នដោយដាក់ប្រាក់ធានា ឬដោយឥតដាក់ប្រាក់ធានា។ សេចក្ដីសម្រេចទាក់ទងនឹងករណីខាងក្រោយនេះត្រូវជូនដំណឹងទៅព្រះរាជអាជ្ញាដែលជាគូក្ដីដើមនៃបណ្ដឹងព្រហ្មទណ្ឌភ្លាម ប្រសិនបើព្រះរាជអាជ្ញាស្នើសុំឲ្យឃុំខ្លួនជនត្រូវចោទក្នុងដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរ។

#### គ.១.១. ការឃុំខ្លួនបណ្ដោះអាសន្ន

គោលបំណងនៃការឃុំខ្លួនបណ្ដោះអាសន្ននេះ គឺដើម្បីរារាំងកុំឲ្យជនត្រូវចោទរត់គេចពីការទទួលខុសត្រូវនៅចំពោះមុខច្បាប់ និងទប់ស្កាត់ការបំផ្លាញភស្តុតាងនានាដែលគេនឹងអាចរកបានក្នុងកិច្ចស៊ើបសួរ ។

ការឃុំខ្លួនបណ្ដោះអាសន្នអាចអនុវត្តបាន តែក្នុងករណីចោទប្រកាន់ពីបទឧក្រិដ្ឋ ឬមជ្ឈិមដែលច្បាប់កំណត់ផ្ដន្ទាទោសដាក់ពន្ធនាគារស្មើ ឬលើសពី១(មួយ)ឆ្នាំ[20]។

ចៅក្រមស៊ើបសួរអាចបង្គាប់ឲ្យឃុំខ្លួនជនត្រូវចោទជាបណ្ដោះអាសន្ន កាលណាការឃុំខ្លួននេះជាវិធានចាំបាច់ដើម្បី៖

១. បញ្ចប់បទល្មើស ឬបង្ការបទល្មើសកុំឲ្យកើតជាថ្មី

២. រារាំងកុំឲ្យមានការគាបសង្កត់លើសាក្សី ឬជនរងគ្រោះ ឬរារាំងកុំឲ្យមានការត្រូវរ៉ូវគ្នារវាងជនត្រូវចោទ និងអ្នកសមគំនិត

៣. រក្សាភស្តុតាង ឬតម្រុយជាសម្ភារៈ

៤. ធានារក្សាជនត្រូវចោទទុកជូនតុលាការចាត់ការតាមនីតិវិធីច្បាប់

៥. ការពារសន្តិសុខឲ្យជនត្រូវចោទ

៦.ធានារក្សាសណ្ដាប់ធ្នាប់សាធារណៈកុំឲ្យមានការច្របូកច្របល់ ដែលបណ្ដាលមកពីបទល្មើស[21]។

ចៅក្រមស៊ើបសួរ អាចសម្រេចអំពីវិធានការឃុំខ្លួនបណ្ដោះអាសន្នដោយគំនិតផ្ដើមរបស់ខ្លួនផ្ទាល់ ឬតាមសេចក្ដីសន្និដ្ឋានរបស់ព្រះរាជអាជ្ញា។ មុននឹងសម្រេចឃុំខ្លួនបណ្ដោះអាសន្នចៅក្រមស៊ើបសួរត្រូវបើកនីតិវិធីឃុំខ្លួនដោយត្រូវមានជនត្រូវចោទ មេធាវីរបស់ជនត្រូវចោទ និងតំណាងអយ្យការចូលរួម ហើយត្រូវប្រាប់ជនត្រូវចោទដើម្បីទទួលការកត់សម្គាល់នានារបស់ជនជាប់ចោទ

[20] មាត្រា២០៤ ក្រមនីតិវិធីព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជាឆ្នាំ២០០៧

[21] មាត្រា២០៥ ក្រមនីតិវិធីព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជាឆ្នាំ២០០៧

ហើយប្រសិនបើជនត្រូវចោទមានមេធាវីអមផង នោះមេធាវីត្រូវបង្ហាញមធ្យោបាយការពារខ្លួនជូនកូនក្តីរបស់ខ្លួន។ ម្យ៉ាងទៀត ចៅក្រមស៊ើបសួរក៏ត្រូវជូនដំណឹងផងដែរដល់ព្រះរាជអាជ្ញា ដើម្បីទទួលយោបល់ និងការកត់សម្គាល់ផ្សេងៗទាក់ទងនឹងការឃុំខ្លួនបណ្តោះអាសន្ននោះ។

ចៅក្រមស៊ើបសួរ សម្រេចឃុំខ្លួនជនត្រូវចោទបណ្តោះអាសន្នតាមរយៈដីកាដោយមានសំអាងហេតុ ហើយដីកានេះត្រូវបានជូនដំណឹងភ្លាមដល់ព្រះរាជអាជ្ញា និងដល់ជនត្រូវចោទ និងមេធាវី[22]។ ចៅក្រមស៊ើបសួរចេញដីកាបង្គាប់ឲ្យឃុំខ្លួនដើម្បីបញ្ជាដល់ប្រធានពន្ធនាគារ ឬមណ្ឌលឃុំខ្លួនឲ្យទទួល និងឃុំខ្លួនជនត្រូវចោទដែលបានកំណត់នៅក្នុងដីកាសម្រេចឲ្យឃុំខ្លួនបណ្តោះអាសន្ន ហើយសាច់ញាតិរបស់ជនជាប់ចោទក៏ត្រូវបានប្រាប់ឲ្យដឹងពីសេចក្តីសម្រេចនេះផងដែរ។

កាលណាចៅក្រមស៊ើបសួរសម្រេចថាពន្យារពេលឃុំខ្លួនជាបណ្តោះអាសន្ន ចៅក្រមនេះត្រូវឲ្យដំណឹងដល់ជនត្រូវចោទ និងទទួលការកត់សម្គាល់របស់ជននោះដូចគ្នានឹងនីតិវិធីនៃការឃុំខ្លួនដែរ ។

កាលណាជនត្រូវចោទមានមេធាវីអមនោះ មេធាវីត្រូវបង្ហាញមធ្យោបាយការពារខ្លួនដល់កូនក្តីរបស់ខ្លួន។ ការពន្យារពេលនៃការឃុំខ្លួនបណ្តោះអាសន្នតាមដីកាដោយមានសំអាងហេតុដែលយោងទៅតាមមូលហេតុនៃការឃុំខ្លួនបណ្តោះអាសន្ន។ ដីកានេះត្រូវឲ្យដំណឹងជាបន្ទាន់ដល់ជនត្រូវចោទបន្ទាប់ពីបានទទួលបណ្តឹងតាមសេចក្តីសន្និដ្ឋានរបស់ព្រះរាជអាជ្ញាដែលសុំឲ្យឃុំខ្លួនបណ្តោះអាសន្ន កាលណាចៅក្រមស៊ើបសួរមិនព្រមសម្រេចឃុំខ្លួនបណ្តោះអាសន្នទៅជនត្រូវចោទតាមរយៈការស្នើសុំទេ នោះចៅក្រមស៊ើបសួរត្រូវចេញដីកាសម្រេចមិនឃុំខ្លួនជាបណ្តោះអាសន្នក្នុងរយៈពេល៥(ប្រាំ)ថ្ងៃ ដោយមិនចាំបាច់មានសំអាងហេតុ ហើយការសម្រេចនេះត្រូវជូនដំណឹងជាបន្ទាន់ដល់ព្រះរាជអាជ្ញា។

ក្នុងករណីដែលចៅក្រមស៊ើបសួរមិនសម្រេចក្នុងរយៈពេល៥(ប្រាំ)ថ្ងៃនោះទេ ព្រះរាជអាជ្ញាអាចប្តឹងទៅសភាស៊ើបសួរដែលនឹងសម្រេចជំនួសចៅក្រមស៊ើបសួរ[23]។

ចំណែកចិរវេលានៃការឃុំខ្លួនជាបណ្តោះអាសន្នចំពោះនីតិជនក្នុងករណីៈ

- បទឧក្រិដ្ឋៈ ការឃុំខ្លួនបណ្តោះអាសន្នមិនលើសពី៦(ប្រាំមួយ)ខែបានទេ។ ប៉ុន្តែនៅពេលផុតចិរវេលានេះ ចៅក្រមស៊ើបសួរអាចពន្យារពេលការឃុំខ្លួនបណ្តោះអាសន្នម្តងបាន៦(ប្រាំមួយ)ខែ ដោយដីកាសំអាងហេតុត្រឹមត្រូវ និងច្បាស់លាស់។ ចៅក្រមស៊ើបសួរអាចសម្រេចពន្យារពេលនៃការឃុំខ្លួនបណ្តោះអាសន្នបានតែ២(ពីរ) ដងគត់[24]។

[22] មាត្រា២០៦ ក្រមនីតិវិធីព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជាឆ្នាំ២០០៧

[23] មាត្រា២០៧ ក្រមនីតិវិធីព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជាឆ្នាំ២០០៧

[24] មាត្រា២០៨ ក្រមនីតិវិធីព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជាឆ្នាំ២០០៧

- បទមជ្ឈិម ៖ ការឃុំខ្លួនបណ្ដោះអាសន្នមិនលើសពី ៤(បួន)ខែ បានទេ។ ប៉ុន្តែនៅពេលផុតថិរវេលានេះ ចៅក្រមស៊ើបសួរអាចពន្យារពេលការឃុំខ្លួនបណ្ដោះអាសន្នបានតែមួយដងគត់ ហើយមិនលើសពី ២(ពីរ)ខែ ដោយដីកាមានសំអាងហេតុត្រឹមត្រូវ និងច្បាស់លាស់។

ថិរវេលានៃការឃុំខ្លួនបណ្ដោះអាសន្នខាងលើមិនត្រូវលើសពីពាក់កណ្ដាលនៃអប្បរមានៃទោសដែលច្បាប់បានកំណត់ឡើយ[25]។

ចំពោះអនីតិជនអាយុតិចជាង១៤(ដប់បួន)ឆ្នាំមិនអាចត្រូវបានអនុញ្ញាតឲ្យឃុំខ្លួនបណ្ដោះអាសន្នបានឡើយ[26]។

ក្នុងករណីដែលផុតថិរវេលាឃុំខ្លួនបណ្ដោះអាសន្ន ចៅក្រមស៊ើបសួរត្រូវចេញដីកាដោះលែងជននោះឲ្យមានសេរីភាពភ្លាម ទោះបីមិនអាចរកឃើញភស្តុតាងណាមួយដើម្បីចោទប្រកាន់ក៏ដោយ។ ក៏ប៉ុន្តែបណ្ដឹងអាជ្ញាអាចនឹងមានតទៅទៀត ប្រសិនបើមិនទាន់ផុតអាជ្ញាយុកាល។

សេចក្ដីសម្រេចដោះលែងឲ្យនៅក្រៅឃុំជាបណ្ដោះអាសន្នអាចធ្វើឡើងដោយពិចារណាលើមូលដ្ឋានដូចតទៅ៖

១.បទល្មើសដែលចោទថាបានប្រព្រឹត្តនោះ ពុំមានលក្ខណៈធ្ងន់ធ្ងរដែលនាំឲ្យមានគ្រោះថ្នាក់ដល់សង្គម

២.ជនត្រូវចោទមានទីលំនៅ និងមុខរបរជាក់លាក់ណាមួយដែលចៅក្រមស៊ើបសួរស្គាល់ដោយមានហេតុផលថាជននោះមិនរត់គេចខ្លួន

៣.កិច្ចស៊ើបសួរ និងការប្រមូលភស្តុតាងសំខាន់ៗត្រូវបានធ្វើចប់សព្វគ្រប់ហើយគ្មាននៅសេសសល់អ្វីដែលអាចបំផ្លាញ ឬកែប្រែដោយជនត្រូវចោទ ហើយសាក្សីដាក់បន្ទុក និងសាក្សីដោះបន្ទុកបានចូលមកបំភ្លឺដោយត្រឹមត្រូវ

៤. បទល្មើសនោះត្រូវបានប្រព្រឹត្តជាលើកដំបូង

៥. ជនត្រូវចោទជាមនុស្សចាស់ជរា ឬស្ត្រីមានផ្ទៃពោះជិតដល់ថ្ងៃសម្រាលកូនជាដើម។

នៅពេលសម្រេចដោះលែងជនជាប់ចោទឲ្យនៅក្រៅឃុំ ចៅក្រមស៊ើបសួរត្រូវចេញដីកាមួយហៅថា ដីកាសម្រេចអនុញ្ញាតឲ្យនៅក្រៅឃុំបណ្ដោះអាសន្ន[27]។

### គ.១.២. ការអនុញ្ញាតឲ្យនៅក្រៅឃុំជាបណ្ដោះអាសន្ន

តាមគោលការណ៍ជនជាប់ចោទដែលស្ថិតនៅក្នុងស្ថានភាពពុំរាងចាល ពិសេសក្នុងបទឧក្រិដ្ឋពុំអាចអនុញ្ញាតឲ្យនៅក្រៅឃុំបណ្ដោះអាសន្នបានទេ។ ចៅក្រមស៊ើបសួរអាចបង្គាប់ឲ្យដោះលែង

---

[25] មាត្រា២០៩ ក្រមនីតិវិធីព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជាឆ្នាំ២០០៧

[26] មាត្រា២១២ ក្រមនីតិវិធីព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជាឆ្នាំ២០០៧

[27] ឧបសម្ព័ន្ធ

ជនត្រូវចោទឲ្យនៅក្រៅឃុំវិញបានគ្រប់ពេលវេលា ហើយកាលណាចៅក្រមស៊ើបសួរមានបំណងដោះលែងជនត្រូវចោទឲ្យនៅក្រៅឃុំនោះចៅក្រមស៊ើបសួរត្រូវជូនព័ត៌មានដល់ព្រះរាជអាជ្ញាដើម្បីសុំយោបល់ ហើយបញ្ជូនសំណុំរឿងទៅឲ្យព្រះរាជអាជ្ញាពិនិត្យ។ ព្រះរាជអាជ្ញាត្រូវផ្តល់យោបល់របស់ខ្លួនក្នុងរយៈពេលយ៉ាងខ្លីបំផុត។ ចៅក្រមស៊ើបសួរសម្រេចយ៉ាងយូរបំផុតក្នុងរយៈពេល៥(ប្រាំ)ថ្ងៃ បន្ទាប់ពីការបញ្ជូនសំណុំរឿងទៅព្រះរាជអាជ្ញា។

ក្នុងករណីបន្ទាន់ចៅក្រមស៊ើបសួរអាចបង្គាប់ឲ្យដោះលែងជនត្រូវចោទភ្លាម ដោយមិនរងចាំយោបល់របស់ព្រះរាជអាជ្ញាឡើយ។ ចៅក្រមស៊ើបសួរចង្អុលប្រាប់មូលហេតុនៃការបន្ទាន់នេះនៅក្នុងដីកាសម្រេចរបស់ខ្លួន[28]។

ព្រះរាជអាជ្ញា ក៏អាចសុំឲ្យដោះលែងជនត្រូវចោទបានគ្រប់ពេលវេលា។ ចៅក្រមស៊ើបសួរត្រូវសម្រេចក្នុងរយៈពេល៥(ប្រាំ)ថ្ងៃ។ ប្រសិនបើ ចៅក្រមស៊ើបសួរមិនបានសម្រេចក្នុងរយៈពេល៥(ប្រាំ)ថ្ងៃទេ ព្រះរាជអាជ្ញាអាចប្តឹងសុំតាមរយៈពាក្យសុំទៅសភាស៊ើបសួរឲ្យសម្រេចជំនួសចៅក្រមស៊ើបសួរ។ ដីកាសម្រេចដែលមិនព្រមដោះលែងត្រូវមានសំអាងហេតុ[29]។

ចំពោះជនត្រូវចោទវិញ ក៏អាចដាក់ពាក្យសុំដោះលែងឲ្យនៅក្រៅឃុំបានគ្រប់ពេលវេលាទៅចៅក្រមស៊ើបសួរ ហើយចៅក្រមស៊ើបសួរត្រូវបញ្ជូនពាក្យសុំនោះភ្លាមទៅឲ្យព្រះរាជអាជ្ញាដើម្បីផ្តល់យោបល់ និងបញ្ជូនរឿងទៅឲ្យព្រះរាជអាជ្ញាដើម្បីពិនិត្យ។ ព្រះរាជអាជ្ញាត្រូវផ្តល់យោបល់ក្នុងរយៈពេលខ្លីបំផុត គឺយ៉ាងយូរបំផុតក្នុងរយៈពេល៥(ប្រាំ)ថ្ងៃ បន្ទាប់ពីពេលបញ្ជូនសំណុំរឿងទៅព្រះរាជអាជ្ញា។ ជនត្រូវចោទអាចដាក់ពាក្យសុំនៅក្រៅឃុំសារជាថ្មីម្តងទៀតទៅចៅក្រមស៊ើបសួរ ឬទៅសភាស៊ើបសួរក្នុងរយៈពេល១(មួយ)ខែបន្ទាប់ពីមានសេចក្តីសម្រេចបដិសេធពាក្យសុំលើកមុន។ ចៅក្រមស៊ើបសួរ ឬសភាស៊ើបសួរត្រូវសម្រេចលើពាក្យសុំនេះក្នុងរយៈពេល៥(ប្រាំ)ថ្ងៃ បន្ទាប់ពីបានទទួលពាក្យសុំ។ ដីកាដែលមិនព្រមដោះលែងឲ្យនៅក្រៅឃុំត្រូវតែមានសំអាងហេតុ។ ប្រសិនបើចៅក្រមស៊ើបសួរមិនបានសម្រេចក្នុងរយៈពេល៥(ប្រាំ)ថ្ងៃទេ ជនត្រូវចោទអាចធ្វើពាក្យប្តឹងដោយផ្ទាល់ទៅសភាស៊ើបសួរដែលអាចសម្រេចជំនួសចៅក្រមស៊ើបសួរបាន។

ដីកាមិនព្រមដោះលែងឲ្យនៅក្រៅឃុំត្រូវតែជូនដំណឹងក្នុងរយៈពេលយ៉ាងខ្លីបំផុតដល់ព្រះរាជអាជ្ញា និងជនត្រូវចោទ។

ដីកាសម្រេចដោះលែងឲ្យនៅក្រៅឃុំត្រូវតែជូនដំណឹងភ្លាមទៅព្រះរាជអាជ្ញា និងដល់ប្រធានពន្ធនាគារ ឬមណ្ឌលឃុំខ្លួនដើម្បីឲ្យដោះលែងជនត្រូវចោទដែលជាប់ឃុំឲ្យមានសេរីភាពតាមបញ្ញត្តិ

[28] មាត្រា២១៥ ក្រមនីតិវិធីព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជាឆ្នាំ២០០៧

[29] មាត្រា២១៦ ក្រមនីតិវិធីព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជាឆ្នាំ២០០៧

មាត្រា២៧៦ នៃក្រមនីតិវិធីព្រហ្មទណ្ឌកម្ពុជា។ ដីកាមិនព្រមដោះលែងឲ្យនៅក្រៅឃុំត្រូវតែជូនដំណឹងក្នុងរយៈពេលខ្លីបំផុតដល់ព្រះរាជអាជ្ញា និងជនត្រូវចោទ។

កាលណាចៅក្រមស៊ើបសួរសម្រេចដោះលែងជនត្រូវចោទឲ្យនៅក្រៅឃុំ ចៅក្រមស៊ើបសួរអាចដាក់ជននោះឲ្យនៅក្រោមការត្រួតពិនិត្យតាមផ្លូវតុលាការក្នុងលក្ខខណ្ឌដូចដែលមានចែងក្នុងមាត្រា២២៣(កាតព្វកិច្ចនៃការដាក់ត្រួតពិនិត្យតាមផ្លូវតុលាការ) ដល់មាត្រា២៣០(ការគេចវេសរបស់ជនត្រូវចោទពីកាតព្វកិច្ចនៃការត្រួតពិនិត្យតាមផ្លូវតុលាការ) នៃក្រមនីតិវិធីព្រហ្មទណ្ឌ[30]។

ចៅក្រមស៊ើបសួរអាចអនុញ្ញាតដាក់ជនត្រូវចោទឲ្យនៅក្រៅឃុំបណ្ដោះអាសន្ន បានដោយចៅក្រមនេះយល់ឃើញថាជនត្រូវចោទមានទីលំនៅច្បាស់លាស់ ហើយជនត្រូវចោទនៅក្រៅឃុំបណ្ដោះអាសន្នមិនរាំងស្ទះដល់ការស៊ើបសួររបស់តុលាការ ឬការដាក់ជនត្រូវចោទឲ្យស្ថិតនៅក្រោមការត្រួតពិនិត្យតាមផ្លូវតុលាការមានលក្ខណៈគ្រប់គ្រាន់ដើម្បីទុកជនត្រូវចោទចាត់ការតាមនីតិវិធី ។

ចៅក្រមស៊ើបសួរអាចដាក់ជនត្រូវចោទឲ្យនៅក្រោមការត្រួតពិនិត្យតាមផ្លូវតុលាការបានគ្រប់ពេលវេលា ប្រសិនបើជនត្រូវចោទនេះត្រូវបានចោទប្រកាន់អំពីបទល្មើស ដែលត្រូវផ្ដន្ទាទោសដាក់ពន្ធនាគារ។ ការត្រួតពិនិត្យតាមផ្លូវតុលាការមានអានុភាពបង្គាប់ជនត្រូវចោទដែលនៅក្រៅឃុំឲ្យគោរពកាតព្វកិច្ចដូចតទៅៈ

១. មិនត្រូវចេញក្រៅព្រំប្រទល់ដែនដីកំណត់ដោយចៅក្រមស៊ើបសួរ

២. មិនត្រូវផ្លាស់ប្ដូរទីលំនៅដោយគ្មានការអនុញ្ញាតពីចៅក្រមស៊ើបសួរ

៣. មិនត្រូវទៅកាន់ទីកន្លែងខ្លះដែលកំណត់ដោយចៅក្រមស៊ើបសួរ

៤. ត្រូវចូលបង្ហាញខ្លួនតាមកាលកំណត់នៅអង្គភាពនគរបាល ឬកងរាជអាវុធហត្ថដែលចាត់តាំងដោយចៅក្រមស៊ើបសួរ

៥. ត្រូវឆ្លើយតបនឹងការកោះហៅពីគ្រប់បុគ្គលដែលចាត់តាំងដោយចៅក្រមស៊ើបសួរ

៦. ប្រគល់ជូនដល់ការិយាល័យក្រឡាបញ្ជីគ្រប់ឯកសារបញ្ជាក់អំពីអត្តសញ្ញាណ

៧. មិនត្រូវបើកបររថយន្ត

៨. មិនត្រូវទទួល ឬជួបបុគ្គលមួយចំនួនដែលចង្អុលបង្ហាញដោយចៅក្រមស៊ើបសួរ

៩. ដាក់ប្រាក់ធានាដែលចំនួននៃប្រាក់ធានា និងចិរវេលាបង់ប្រាក់នេះត្រូវបានកំណត់ដោយចៅក្រមស៊ើបសួរដោយផ្អែកលើធនធានរបស់ជនត្រូវចោទ

១០. មិនត្រូវកាន់កាប់ ឬយកតាមខ្លួននូវអាវុធ (ប្រសិនបើមានត្រូវប្រគល់ជូនដល់ការិយាល័យក្រឡាបញ្ជីនូវអាវុធដែលខ្លួនកាន់កាប់ )

[30] មាត្រា២១៨ ក្រមនីតិវិធីព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជាឆ្នាំ២០០៧

១១.ត្រូវប្រគល់ខ្លួនឲ្យពេទ្យពិនិត្យព្យាបាល និងជាយថាហេតុដាក់ឲ្យស្ថិតនៅក្រោមរបបព្យាបាលរោគក្នុងមន្ទីរពេទ្យ

១២. មិនត្រូវធ្វើសកម្មភាពខាងវិជ្ជាជីវៈខ្លះៗ។

ក៏ប៉ុន្តែចៅក្រមស៊ើបសួរមិនអាចហាមឃាត់ការចូលរួមបោះឆ្នោត ឬសកម្មភាពខាងសហជីពបានទេ[31]។

អនីតិជនអាយុតិចជាង ១៤(ដប់បួន)ឆ្នាំ មិនអាចត្រូវដាក់ឲ្យស្ថិតនៅក្រោមការត្រួតពិនិត្យតាមផ្លូវតុលាការបានទេ[32]។

សេចក្តីសម្រេចឃុំខ្លួនជាបណ្តោះអាសន្នមានអានុភាពអនុវត្តភ្លាមៗ ទោះបីមានការជំទាស់យ៉ាងណាក៏ដោយ ទោះបីជាបណ្តឹងឧទ្ធរណ៍របស់ព្រះរាជអាជ្ញាក៏ដោយ។ កាលណាចៅក្រមស៊ើបសួរសម្រេចដោះលែងជនត្រូវចោទដែលជាប់ឃុំបណ្តោះអាសន្ន ជនត្រូវចោទនោះត្រូវបានរក្សាទុកនៅក្នុងពន្ធនាគាររហូតដល់ផុតរយៈពេលសម្រាប់បណ្តឹងឧទ្ធរណ៍របស់ព្រះរាជអាជ្ញា លើកលែងតែព្រះរាជអាជ្ញាយល់ព្រមឲ្យដោះលែងជនត្រូវចោទនោះភ្លាម។ សេចក្តីសម្រេចជាលាយលក្ខណ៍អក្សររបស់ព្រះរាជអាជ្ញាត្រូវដាក់បញ្ចូលទៅក្នុងសំណុំរឿងនៃនីតិវិធី។ ក្នុងករណីមានបណ្តឹងឧទ្ធរណ៍របស់ព្រះរាជអាជ្ញាអំពីដីកាដោះលែងឲ្យនៅក្រៅឃុំ ឬលើកលែងការចោទប្រកាន់នោះជនត្រូវចោទដែលជាប់ឃុំត្រូវបានរក្សាទុកក្នុងពន្ធនាគាររហូតទាល់តែសភាស៊ើបសួរបានសម្រេចអំពីបណ្តឹងឧទ្ធរណ៍[33]។

**គ.២. ការកោះហៅឲ្យមកបង្ហាញខ្លួន**

ជាដំបូងចៅក្រមស៊ើបសួរកោះហៅជនសង្ស័យឲ្យចូលមកតុលាការដើម្បីសាកសួរយកចម្លើយតាមដីកាបង្គាប់ឲ្យចូលខ្លួន។ ជនរងគ្រោះដើមបណ្តឹងរដ្ឋប្បវេណីអ្នកទទួលខុសត្រូវខាងរដ្ឋប្បវេណី និងសាក្សីក៏ត្រូវហៅមកសាកសួរយកព័ត៌មានដែរតាមរយៈដីកាកោះនេះ។ ក្នុងដំណាក់កាលនេះចៅក្រមស៊ើបសួរអាចចេញដីកាកោះ ដីកាបង្គាប់ឲ្យចូលខ្លួន ដីកាបង្គាប់ឲ្យនាំខ្លួន និងដីកាបង្គាប់ឲ្យចាប់ខ្លួនទៅតាមករណីសមស្របនីមួយៗ។ ក្នុងដំណាក់កាលនេះផងដែរ ប្រសិនបើជនដែលចៅក្រមស៊ើបសួរកោះហៅនោះបានចូលខ្លួនមកហើយ ចៅក្រមស៊ើបសួរអាចបើកកិច្ចស៊ើបសួរ ដោយឃើញថាជននោះមានភាពស៊ីសង្វាក់ទៅនឹងបទល្មើស ព្រមទាំងមានភស្តុតាងគ្រប់គ្រាន់ដើម្បីដាក់បន្ទុកជននោះ ចៅក្រមស៊ើបសួរក៏អាចចេញដីកាសម្រេចឃុំខ្លួនជននោះបានដែរ ដោយមានការស្នើសុំឲ្យចោទប្រកាន់ និងឲ្យឃុំខ្លួនពីសំណាក់ព្រះរាជអាជ្ញាផងទៅតាមនីតិវិធីដូចនៅក្នុងចំណុចនៃការឃុំខ្លួនបណ្តោះអាសន្នដែរ។ ក្នុងសេចក្តីនៃដីកាត្រូវបញ្ជាក់ប្រាប់ឈ្មោះចៅក្រមស៊ើបសួរ និងហត្ថលេខារបស់

[31] មាត្រា២២៣ ក្រមនីតិវិធីព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជាឆ្នាំ២០០៧

[32] មាត្រា២៣៤ ក្រមនីតិវិធីព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជាឆ្នាំ២០០៧

[33] មាត្រា២៧៦ ក្រមនីតិវិធីព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជាឆ្នាំ២០០៧

ចៅក្រម នាម និងគោត្តនាម អត្រានុកូលដ្ឋានរបស់ជនជាប់ចោទ ភិនភាគរបស់ជនជាប់ចោទ និងឈ្មោះឪពុកម្តាយរបស់ជនត្រូវចោទ ដើម្បីជៀសវាងការពិបាករកជននោះ ឬអាចនឹងយល់ច្រឡំទៅលើបុគ្គលផ្សេង។

### គ.២.១. ដីកាកោះ[34]

ដីកាកោះ គឺជាលិខិតបង្គាប់របស់តុលាការដែលតម្រូវឲ្យបុគ្គលណាមួយត្រូវតែមកបង្ហាញខ្លួននៅតុលាការតាមកាលបរិច្ឆេទដែលបានកំណត់។ ដីកាកោះនេះគេប្រើសម្រាប់កោះហៅជនរងគ្រោះ អ្នកទទួលខុសត្រូវរដ្ឋប្បវេណី ដើមបណ្តឹងរដ្ឋប្បវេណី អ្នកជំនាញ អ្នកបកប្រែ និងសាក្សី ឲ្យចូលខ្លួនដោយស្ម័គ្រចិត្តចំពោះមុខតុលាការ។

ដីកាកោះទាំងនេះត្រូវមានចុះនិទ្ទេសដូចតទៅៈ

- អត្តសញ្ញាណនៃជនដែលពាក់ព័ន្ធ
- លំនៅឋាននៃជនដែលពាក់ព័ន្ធ
- ឈ្មោះជនជាប់ចោទ និងបទល្មើសដែលត្រូវចោទប្រកាន់
- តុលាការដែលត្រូវជំនុំជម្រះ
- ទីកន្លែង កាលបរិច្ឆេទ និងម៉ោងនៃសវនាការ
- កាលបរិច្ឆេទ និងហត្ថលេខារបស់ព្រះរាជអាជ្ញា

ដីកាកោះទាំងនេះត្រូវបញ្ជាក់ថាបុគ្គលដែលពាក់ព័ន្ធត្រូវបានកោះហៅក្នុងឋានៈជាជនរងគ្រោះ ដើមបណ្តឹងរដ្ឋប្បវេណី អ្នកទទួលខុសត្រូវខាងរដ្ឋប្បវេណី អ្នកជំនាញ អ្នកបកប្រែ ឬសាក្សី[35]។ បុគ្គលគ្រប់រូបដែលត្រូវបានចៅក្រមស៊ើបសួរកោះហៅក្នុងឋានៈជាសាក្សីត្រូវតែមកបង្ហាញខ្លួន។ ក្នុងករណីរឹងទទឹង ចៅក្រមស៊ើបសួរអាចសុំឲ្យកងកម្លាំងសាធារណៈបង្ខំសាក្សីនេះឲ្យចូលមកបង្ហាញខ្លួនបាន។ ចៅក្រមស៊ើបសួរអាចចេញបញ្ជាឲ្យចូលមកបង្ហាញខ្លួន ហើយបញ្ជានេះត្រូវមានអត្តសញ្ញាណរបស់សាក្សី ហើយត្រូវចុះកាលបរិច្ឆេទ និងចុះហត្ថលេខាដោយចៅក្រមស៊ើបសួរ និងមានបោះត្រាផង។

### គ.២.២.ដីកាបង្គាប់ឲ្យចូលខ្លួន[36]

ចៅក្រមស៊ើបសួរអាចចេញដីកាបង្គាប់ឲ្យចូលខ្លួន[37]។ ដីកាបង្គាប់ឲ្យចូលខ្លួនគឺជាបញ្ជាដល់បុគ្គលណាម្នាក់ឲ្យចូលទៅបង្ហាញខ្លួននៅចំពោះមុខចៅក្រមស៊ើបសួរ។ ដីកាបង្គាប់ឲ្យចូលខ្លួនអាចចេញទៅលើជនត្រូវចោទ ឬបុគ្គលណាម្នាក់ដែលមានតម្រុយពិរុទ្ធភាព។

[34] ឧបសម្ព័ន្ធ
[35] មាត្រា៤៧៥ដល់មាត្រា៤៨០ ក្រមនីតិវិធីព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជាឆ្នាំ២០០៧
[36] ឧបសម្ព័ន្ធ
[37] មាត្រា១៨៦ ក្រមនីតិវិធីព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជាឆ្នាំ២០០៧

ដីកាបង្គាប់ឲ្យចូលខ្លួនត្រូវមាននិទ្ទេសដូចតទៅ[38]៖

- អត្តសញ្ញាណនៃបុគ្គលដែលពាក់ព័ន្ធ
- បទល្មើសដែលចោទប្រកាន់ និងអត្ថបទច្បាប់ដែលកំណត់ និងបង្ក្រាបបទល្មើសនោះ
- ថ្ងៃ ខែ ឆ្នាំ ម៉ោង និងទីកន្លែងដែលត្រូវចូលបង្ហាញខ្លួននៅមុខចៅក្រមស៊ើបសួរ
- ឈ្មោះ និងឋានៈរបស់ចៅក្រមដែលចេញដីកា។

ដីកាបង្គាប់ឲ្យចូលខ្លួនត្រូវមានចុះកាលបរិច្ឆេទ និងចុះហត្ថលេខាដោយចៅក្រមស៊ើបសួរ និងមានបោះត្រាផង។

ដីកាបង្គាប់ឲ្យចូលខ្លួន ត្រូវឲ្យដំណឹងដល់បុគ្គលដែលពាក់ព័ន្ធដោយមន្ត្រីនគរបាលយុត្តិធម៌ ភ្នាក់ងារនគរបាលយុត្តិធម៌ ឬដោយអាជ្ញាសាលា[39]។ បុគ្គលដែលពាក់ព័ន្ធទទួលចុងដីកា ហើយត្រូវចុះហត្ថលេខានៅលើដើមដីកាដែលត្រូវបង្វិលជូនចៅក្រមស៊ើបសួរវិញ។ មន្ត្រីនគរបាលយុត្តិធម៌ ភ្នាក់ងារនគរបាលយុត្តិធម៌ ឬដោយអាជ្ញាសាលាត្រូវជូនដំណឹងដល់ចៅក្រមស៊ើបសួរអំពីគ្រប់ការលំបាកក្នុងការអនុវត្តបេសកកម្មរបស់ខ្លួន។ ដីកានេះប្រើសម្រាប់កោះហៅជនជាប់សង្ស័យដែលព្រះរាជអាជ្ញាបានផ្តើមចោទប្រកាន់។ ដីកាបង្គាប់ឲ្យចូលខ្លួនដាក់លក្ខខណ្ឌព្រមានដល់ជនជាប់ចោទថា បើមិនចូលខ្លួនតុលាការនឹងចាត់វិធានការប្រើកម្លាំងសាធារណៈបង្ខំឲ្យចូលខ្លួន។

### គ.២.៣. ដីកាបង្គាប់ឲ្យនាំខ្លួន [40]

ប្រសិនបើដីកាបង្គាប់ឲ្យចូលខ្លួនត្រូវបានទទួលដោយត្រឹមត្រូវពីសំណាក់ជនជាប់សង្ស័យ ឬជនត្រូវចោទ ហើយជននេះនៅតែរឹងទទឹងមិនព្រមចូលមកតុលាការតាមថ្ងៃ និងពេលកំណត់ទេនោះ ចៅក្រមស៊ើបសួរអាចចេញដីកាមួយទៀតហៅថា **ដីកាបង្គាប់ឲ្យនាំខ្លួន** ។

ចៅក្រមស៊ើបសួរអាចចេញដីកាបង្គាប់ឲ្យនាំខ្លួន[41]។ ដីកាបង្គាប់ឲ្យនាំខ្លួន គឺជាបញ្ជាដល់កងកម្លាំងសាធារណៈឲ្យចាប់ និងនាំខ្លួនបុគ្គលណាម្នាក់ទៅចំពោះមុខចៅក្រមស៊ើបសួរ។

ដីកាបង្គាប់ឲ្យនាំខ្លួនអាចត្រូវចេញទៅលើជនត្រូវចោទ ឬទៅលើបុគ្គលណាម្នាក់ដែលមានតម្រុយពិរុទ្ធភាព[42]។

ដីកាបង្គាប់ឲ្យនាំខ្លួនត្រូវមានចុះនិទ្ទេសដូចតទៅ[43]៖

- អត្តសញ្ញាណនៃបុគ្គលដែលពាក់ព័ន្ធ

---

[38] មាត្រា១៨៧ ក្រមនីតិវិធីព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជាឆ្នាំ២០០៧

[39] មាត្រា១៨៨ ក្រមនីតិវិធីព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជាឆ្នាំ២០០៧

[40] ឧបសម្ព័ន្ធ

[41] មាត្រា១៨៩ ក្រមនីតិវិធីព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជាឆ្នាំ២០០៧

[42] មាត្រា១៩០ ក្រមនីតិវិធីព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជាឆ្នាំ២០០៧

[43] មាត្រា១៩១ ក្រមនីតិវិធីព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជាឆ្នាំ២០០៧

- បទល្មើសដែលចោទប្រកាន់ និងអត្ថបទច្បាប់ដែលកំណត់ និងបង្ក្រាបបទល្មើសនេះ
- ឈ្មោះ និងឋានៈរបស់ចៅក្រមដែលចេញដីកា។

ដីកាបង្គាប់ឲ្យនាំខ្លួននេះត្រូវមានចុះកាលបរិច្ឆេទ និងចុះហត្ថលេខាដោយចៅក្រមស៊ើបសួរ និងមានបោះត្រាផង។

ការអនុវត្តដីកាបង្គាប់ឲ្យនាំខ្លួនត្រូវប្រគល់ឲ្យមន្ត្រីនគរបាលយុត្តិធម៌។ ក្នុងករណីបន្ទាន់ដីកាបង្គាប់ឲ្យនាំខ្លួនត្រូវផ្សព្វផ្សាយដល់អង្គភាពនគរបាល ឬកងរាជអាវុធហត្ថទៅតាមគ្រប់មធ្យោបាយ។

ដើមដីកានេះ ត្រូវប្រគល់ជូនជាបន្ទាន់ដល់មន្ត្រីនគរបាលយុត្តិធម៌ដែលទទួលបន្ទុកអនុវត្តដីកានេះ។ មន្ត្រីនគរបាលយុត្តិធម៌មិនអាចចូលទៅក្នុងលំនៅឋានរបស់បុគ្គលដែលពាក់ព័ន្ធមុនម៉ោង ៦(ប្រាំមួយ)ព្រឹក និងក្រោយម៉ោង ១៨(ដប់ប្រាំបី)ល្ងាចបានទេ។ មន្ត្រីនគរបាលយុត្តិធម៌ត្រូវជូនដំណឹងដល់ចៅក្រមស៊ើបសួរអំពីការលំបាកក្នុងការអនុវត្តបេសកកម្មរបស់ខ្លួន[44]។

ប្រសិនបើដោយមូលហេតុនៃកាលៈទេសៈបុគ្គលដែលពាក់ព័ន្ធមិនអាចត្រូវបាននាំទៅបង្ហាញខ្លួនដល់ចៅក្រមស៊ើបសួរក្រោយពេលចាប់ខ្លួនបានទេ បុគ្គលនេះត្រូវតែនាំខ្លួនទៅក្នុងអង្គភាពនគរបាល ឬកងរាជអាវុធហត្ថក្នុងមណ្ឌលឃុំខ្លួន ឬទៅក្នុងពន្ធនាគារ។ បុគ្គលនេះត្រូវតែនាំទៅបង្ហាញខ្លួនយ៉ាងយូរត្រឹមថ្ងៃបន្ទាប់ដល់ចៅក្រមស៊ើបសួរ។ ប្រសិនបើការបង្ហាញខ្លួនមិនបានប្រព្រឹត្តទៅនៅថ្ងៃបន្ទាប់ទេ បុគ្គលដែលពាក់ព័ន្ធត្រូវតែដោះលែងឲ្យមានសេរីភាពវិញ[45]។

### គ.២.៤. ដីកាបង្គាប់ឲ្យចាប់ខ្លួន [46]

ប្រសិនបើជនជាប់សង្ស័យមិនត្រូវបាននាំខ្លួនឲ្យចូលមកកាន់តុលាការទេ ដោយគេចខ្លួនបាត់ពីលំនៅឋាន ហើយច្បាប់ដើមនៃដីកាបង្គាប់ឲ្យនាំខ្លួនត្រូវបានផ្ញើរត្រឡប់មកចៅក្រមស៊ើបសួរវិញដោយភ្ជាប់ជាមួយក្រដាសសារតាជាតិដែលមានចុះអត្តសញ្ញាណជនជាប់ចោទពេញលេញនោះ ចៅក្រមស៊ើបសួរអាចចេញដីកាបង្គាប់ឲ្យចាប់ខ្លួនក្រោយពីមានសេចក្តីសន្និដ្ឋានឲ្យចាប់ខ្លួនពីព្រះរាជអាជ្ញា[47] ។

តាមធម្មតា និងតាមបច្ចេកទេសបង្កសំណុំរឿងជនជាប់សង្ស័យដែលបានគេចខ្លួនបាត់ ដូច្នេះចៅក្រមស៊ើបសួរមិនត្រូវទុកសំណុំរឿងរងចាំឲ្យយឺតយូរឡើយ គឺប្រសិនបើយល់ថាកិច្ចស៊ើបសួរមូលគ្រប់គ្រាន់ ហើយចៅក្រមស៊ើបសួរត្រូវធ្វើដីកាបញ្ជូនសំណុំរឿងពិនិត្យមូលដាក់ជូនទៅព្រះរាជអាជ្ញាពិនិត្យ ដើម្បីឲ្យព្រះរាជអាជ្ញាមានលទ្ធភាពសន្និដ្ឋានអំពីការចាប់ខ្លួនបុគ្គលដែលជាប់សង្ស័យនោះ។

---

[44] មាត្រា១៩២ ក្រមនីតិវិធីព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជាឆ្នាំ២០០៧

[45] មាត្រា១៩៣ ក្រមនីតិវិធីព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជាឆ្នាំ២០០៧

[46] ឧបសម្ព័ន្ធ

[47] មាត្រា១៩៥ ក្រមនីតិវិធីព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជាឆ្នាំ២០០៧

ដីកាបង្គាប់ឲ្យចាប់ខ្លួនអាចត្រូវចេញទៅលើជនត្រូវចោទ ឬបុគ្គលណាម្នាក់ដែលមានតម្រុយពិរុទ្ធភាព។ ចៅក្រមស៊ើបសួរនឹងអាចចេញដីកាបង្គាប់ឲ្យចាប់ខ្លួនបានលុះត្រាតែ៖

១. បទល្មើសដែលចោទប្រកាន់ជាបទឧក្រិដ្ឋ ឬបទមជ្ឈិមដែលត្រូវផ្តន្ទាទោសដាក់ពន្ធនាគារ

២. បុគ្គលដែលពាក់ព័ន្ធបានគេចខ្លួនបាត់មិនដឹងជាស្ថិតនៅកន្លែងណា ឬស្ថិតនៅក្រៅដែនដីនៃព្រះរាជាណាចក្រកម្ពុជា។

ដីកាបង្គាប់ឲ្យចាប់ខ្លួនគឺជាបញ្ជា៖

- ដល់កងកម្លាំងសាធារណៈឲ្យស្រាវជ្រាវរកចាប់ និងឲ្យនាំខ្លួនបុគ្គលនោះទៅក្នុងពន្ធនាគារ ឬមណ្ឌលឃុំខ្លួន។
- ដល់ប្រធានពន្ធនាគារ ឬមណ្ឌលឃុំខ្លួនឲ្យទទួល និងឃុំខ្លួនបុគ្គលនោះ[48]។

មុននឹងចេញដីកាបង្គាប់ឲ្យចាប់ខ្លួនចៅក្រមស៊ើបសួរត្រូវតែទទួលយោបល់ពីព្រះរាជអាជ្ញា។ ចៅក្រមស៊ើបសួរត្រូវចេញដីកានេះដោយមានចែងមូលហេតុក្រោយពីទទួលយកយោបល់ពីព្រះរាជអាជ្ញា។ ព្រះរាជអាជ្ញា ជាអ្នកធានារ៉ាប់រងដីកាបង្គាប់ឲ្យចាប់ខ្លួន[49]។

ដីកាបង្គាប់ឲ្យចាប់ខ្លួនមាននិទ្ទេសដូចតទៅ[50]៖

- អត្តសញ្ញាណនៃបុគ្គលដែលពាក់ព័ន្ធ
- បទល្មើសដែលចោទប្រកាន់ និងអត្ថបទច្បាប់ដែលកំណត់ និងបង្ក្រាបបទល្មើសនេះ
- ឈ្មោះ និងឋានៈរបស់ចៅក្រមដែលចេញដីកា។

ដីកាបង្គាប់ឲ្យចាប់ខ្លួនត្រូវមានចុះកាលបរិច្ឆេទ និងចុះហត្ថលេខាដោយចៅក្រមស៊ើបសួរ និងមានបោះត្រាផង។ ការអនុវត្តដីកាបង្គាប់ឲ្យចាប់ខ្លួនត្រូវប្រគល់ឲ្យទៅមន្ត្រីនគរបាលយុត្តិធម៌។ ក្នុងករណីបន្ទាន់ដីកាបង្គាប់ឲ្យចាប់ខ្លួនត្រូវផ្សព្វផ្សាយដល់អង្គភាពនគរបាល ឬកងរាជអាវុធហត្ថតាមគ្រប់មធ្យោបាយ។ ដើមដីកាត្រូវប្រគល់ក្នុងរយៈពេលដ៏ខ្លីបំផុតឲ្យដល់មន្ត្រីនគរបាលយុត្តិធម៌ដែលទទួលបន្ទុកអនុវត្តដីកានោះ។ មន្ត្រីនគរបាលយុត្តិធម៌មិនអាចចូលទៅក្នុងលំនៅឋានរបស់បុគ្គលដែលពាក់ព័ន្ធមុនម៉ោង ៦(ប្រាំមួយ)ព្រឹក និង ក្រោយម៉ោង ១៨(ដប់ប្រាំបី)ល្ងាចបានទេ។ មន្ត្រីនគរបាលយុត្តិធម៌ត្រូវជូនដំណឹងដល់ចៅក្រមស៊ើបសួរអំពីការលំបាកក្នុងការអនុវត្តបេសកកម្មរបស់ខ្លួន។ ករណីចាំបាច់ដីកាបង្គាប់ឲ្យចាប់ខ្លួនអាចផ្សព្វផ្សាយជាអន្តរជាតិតាមរយៈក្រសួងយុត្តិធម៌ដោយប្រើយន្តការនានាដែលមានប្រសិទ្ធភាព[51]។

[48] មាត្រា១៩៦ ក្រមនីតិវិធីព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជាឆ្នាំ២០០៧

[49] មាត្រា១៩៧ ក្រមនីតិវិធីព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជាឆ្នាំ២០០៧

[50] មាត្រា១៩៨ ក្រមនីតិវិធីព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជាឆ្នាំ២០០៧

[51] មាត្រា១៩៩ ក្រមនីតិវិធីព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជាឆ្នាំ២០០៧

ការបង្ហាញខ្លួនតាមដីកាបង្គាប់ឲ្យចាប់ខ្លួនប្រធានពន្ធនាគារ ឬមណ្ឌលឃុំខ្លួនត្រូវតែទទួល និងឃុំខ្លួនជនត្រូវចោទដែលជាកម្មវត្ថុនៃដីកាបង្គាប់ឲ្យចាប់ខ្លួន។ ប្រធានពន្ធនាគារ ឬមណ្ឌលឃុំខ្លួនរក្សាទុកដើមដីកា ឬចុងដីកាដែលមានបញ្ជាក់ថាត្រឹមត្រូវតាមច្បាប់ដើម[52]។

បុគ្គលដែលពាក់ព័ន្ធត្រូវតែបានគេនាំទៅបង្ហាញចៅក្រមស៊ើបសួរក្នុងរយៈពេលយ៉ាងខ្លីបំផុត ប្រសិនបើស្ថិតនៅក្នុងដំណាក់កាលស៊ើបសួរនៅឡើយ។

ប្រសិនបើការនាំខ្លួនទៅបង្ហាញនេះតម្រូវឲ្យមានការផ្ទេរបុគ្គលពាក់ព័ន្ធទៅពន្ធនាគារ ឬទៅមណ្ឌលឃុំខ្លួនមួយផ្សេងទៀតការផ្ទេរនេះត្រូវចាត់ចែងដោយអយ្យការ។

ប្រសិនបើបុគ្គលដែលពាក់ព័ន្ធមិនត្រូវបានគេនាំខ្លួនទៅបង្ហាញដល់ចៅក្រមស៊ើបសួរ ឬអ្នកជំនួសចៅក្រមស៊ើបនៅថ្ងៃបន្ទាប់ពីការចាប់ខ្លួនបុគ្គលនេះត្រូវតែបានព្រះរាជអាជ្ញានាទីកន្លែងឃុំខ្លួនស្តាប់ចម្លើយ បន្ទាប់មកព្រះរាជអាជ្ញានេះត្រូវធ្វើកំណត់ហេតុស្តាប់ចម្លើយដែលត្រូវបញ្ជូនទៅចៅក្រមស៊ើបសួរ។

**កថាខណ្ឌទី២៖ ការបញ្ជូនលទ្ធផលស៊ើបសួរទៅឲ្យព្រះរាជអាជ្ញាពិនិត្យ**

នៅពេលដែលចៅក្រមស៊ើបសួរបានធ្វើការស៊ើបសួរចប់សព្វគ្រប់ហើយ ចៅក្រមស៊ើបសួរត្រូវទុកសំណុំរឿងឲ្យមេធាវីរបស់ជនជាប់ចោទពិនិត្យតាមសេចក្តីត្រូវការក្នុងរយៈពេល២៤(ម្ភៃបួន)ម៉ោង។ បន្ទាប់ពីនោះចៅក្រមស៊ើបសួរត្រូវរៀបចំដីកាមួយហៅថា ដីកាបញ្ជូនរឿងទៅពិនិត្យ[53] រួចភ្ជាប់សំណុំរឿងជាមួយដីកានេះដើម្បីដាក់ជូនទៅព្រះរាជអាជ្ញាធ្វើសេចក្តីសន្និដ្ឋានលើដីកាសន្និដ្ឋានស្តាពរលើអង្គហេតុដែលចៅក្រមស៊ើបសួរបានរកឃើញដែលក្នុងនោះរួមមាន៖

- សេចក្តីថ្លែងពីអង្គហេតុ
- ចម្លើយបំភ្លឺបានពីជនដែលពាក់ព័ន្ធ៖
  ក). ដើមបណ្តឹងរដ្ឋប្បវេណី ជនរងគ្រោះ ឬអ្នកតំណាង
  ខ). ចម្លើយសាក្សីរបស់ដើមចោទ
  គ). ចម្លើយរបស់សាក្សីបំភ្លឺ
  ឃ). ចម្លើយរបស់សាក្សីជនជាប់ចោទ
  ង). ចម្លើយរបស់ជនជាប់ចោទ។
- ឯកសារនានា និងវត្ថុតាងផ្សេងៗទៀត។

[52] មាត្រា២០១ ក្រមនីតិវិធីព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជាឆ្នាំ២០០៧

[53] ឧបសម្ព័ន្ធ

## ផ្នែកទី៣៖ ការបិទការស៊ើបសួររបស់ចៅក្រមស៊ើបសួរ

នៅពេលដែលចៅក្រមស៊ើបសួរយល់ឃើញថា ការស៊ើបសួរមូលចប់សព្វគ្រប់ហើយ ចៅក្រមស៊ើបសួរបិទសំណុំរឿងក្រោមកិច្ចមួយហៅថា ដីកាដំណោះស្រាយ[54]។ ប៉ុន្តែបើការស៊ើបសួរបានអូសបន្លាយអស់រយៈពេល ១(មួយ)ឆ្នាំ ជនត្រូវចោទ ឬដើមបណ្តឹងរដ្ឋប្បវេណីអាចសុំឲ្យចៅក្រមស៊ើបសួរធ្វើការបិទការស៊ើបសួរបាន។ មិនត្រឹមតែប៉ុណ្ណោះព្រះរាជអាជ្ញាក៏អាចសុំឲ្យចៅក្រមស៊ើបសួរធ្វើការបញ្ចប់ការស៊ើបសួរបានដែរ។ ចៅក្រមស៊ើបសួរពិនិត្យ វាយតម្លៃ ដោយអធិបតេយ្យនូវខណៈពេលដែលត្រូវបញ្ចប់ការស៊ើបសួរនៅពេលដែលចៅក្រមស៊ើបសួរយល់ឃើញថាការរកភស្តុតាងមិនតម្រូវឲ្យមានកិច្ចស្រាវជ្រាវអ្វីមួយបន្ថែមទៀតទេ។

### កថាខណ្ឌទី១ ៖ ការបញ្ចប់ការស៊ើបសួរ

#### ក. ការជូនដំណឹងទៅភាគី

កាលណាចៅក្រមស៊ើបសួរយល់ឃើញថាការស៊ើបសួរបានបញ្ចប់ ចៅក្រមស៊ើបសួរត្រូវជូនព័ត៌មាននេះដល់ព្រះរាជអាជ្ញា ជនត្រូវចោទ ដើមបណ្តឹងរដ្ឋប្បវេណី និងមេធាវី ហើយក្នុងរយៈពេល ២(ពីរ)ថ្ងៃក្រោយមកចៅក្រមស៊ើបសួរបញ្ជូនសំណុំរឿងឲ្យទៅព្រះរាជអាជ្ញាដើម្បីពិនិត្យ។

##### ក.១. ការសន្និដ្ឋានរបស់អយ្យការចំពោះលទ្ធផលរបស់ចៅក្រមស៊ើបសួរ

ព្រះរាជអាជ្ញាក្រោយពីបានទទួលសំណុំរឿងតាមរយៈដីកាបញ្ជូនរឿងទៅពិនិត្យមូលរបស់ចៅក្រមស៊ើបសួរហើយ ព្រះរាជអាជ្ញាត្រូវធ្វើសេចក្តីសន្និដ្ឋានស្ថាពរមុនតាមរយៈដីកាសន្និដ្ឋានស្ថាពរ ។

##### ក.២. ដីកាសន្និដ្ឋានស្ថាពររបស់ព្រះរាជអាជ្ញា

ប្រសិនបើព្រះរាជអាជ្ញាយល់ឃើញថាចាំបាច់ត្រូវធ្វើកិច្ចស៊ើបសួរថ្មីទៀតនោះ ព្រះរាជអាជ្ញាត្រូវធ្វើតាមរយៈការស្នើសុំឲ្យបំពេញកិច្ចដោយព្រះរាជអាជ្ញា ដែលមានចែងនៅក្នុងមាត្រា ១៣២នៃក្រមនីតិវិធីព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជាឆ្នាំ២០០៧។

នៅក្នុងរយៈពេល១៥(ដប់ប្រាំ)ថ្ងៃ ប្រសិនបើជនត្រូវចោទត្រូវឃុំខ្លួន និង១(មួយ)ខែ ក្នុងករណីដែលជនត្រូវចោទនៅក្រៅឃុំព្រះរាជអាជ្ញាអាចបង្វិលសំណុំរឿងទៅចៅក្រមស៊ើបសួរវិញ ដោយមានដីកាសន្និដ្ឋានស្ថាពរភ្ជាប់ជាមួយផង។ ចិរវេលានេះត្រូវគិតពីថ្ងៃដែលព្រះរាជអាជ្ញាបានទទួលសំណុំរឿង។ ប្រសិនបើព្រះរាជអាជ្ញាយល់ឃើញដូចចៅក្រមស៊ើបសួរដែរ ថាការស៊ើបសួរត្រូវបញ្ចប់នោះ ព្រះរាជអាជ្ញានឹងធ្វើដីកាសន្និដ្ឋានស្ថាពរជាលាយលក្ខណ៍អក្សរ និងមានសំអាងហេតុ។

ព្រះរាជអាជ្ញាអាចប្តឹងសុំឲ្យចៅក្រមស៊ើបសួរ ដើម្បីបញ្ជូនខ្លួនជនត្រូវចោទទៅកាន់តុលាការជំនុំជម្រះក្តី ឬក៏លើកលែងការចោទប្រកាន់[55]។

---

[54] ឧបសម្ព័ន្ធ

[55] មាត្រា២៤៦ ក្រមនីតិវិធីព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជាឆ្នាំ២០០៧

បន្ទាប់មកចៅក្រមស៊ើបសួរត្រូវធ្វើដីកាសម្រេចតាមរយៈដីកាដំណោះស្រាយបញ្ជូនជនត្រូវចោទទៅជំនុំជម្រះ ឬលើកលែងការចោទប្រកាន់ ទោះបីចៅក្រមស៊ើបសួរយល់ស្រប ឬមិនយល់ស្របនឹងដីកាសន្និដ្ឋានរបស់ព្រះរាជអាជ្ញាដ៏ដោយ។

**ខ. ការសម្រេចរបស់ចៅក្រមស៊ើបសួរ**

នៅក្នុងដំណាក់កាលនេះ ចៅក្រមស៊ើបសួរអាចមានលទ្ធភាពច្រើនដូចជា៖

ករណីទី១៖ ក្នុងករណីចៅក្រមស៊ើបសួរចេញដីកាលើកលែងការចោទប្រកាន់ ហើយប្រសិនបើព្រះរាជអាជ្ញាមិនយល់ស្របនឹងសេចក្តីសម្រេចនោះទេ ព្រះរាជអាជ្ញាអាចប្តឹងទៅឧទ្ធរណ៍ក្នុងរយៈពេល ៥(ប្រាំ)ថ្ងៃ ចាប់ពីថ្ងៃជូនដំណឹងអំពីដីកានេះ[56]។

នៅក្នុងរយៈពេលនៃការប្តឹងឧទ្ធរណ៍នេះបើជនជាប់ចោទស្ថិតនៅក្នុងការឃុំខ្លួនបណ្តោះអាសន្ននោះគឺនៅជាប់ឃុំខ្លួនដដែលរហូតដល់មានសេចក្តីសម្រេចរបស់សភាស៊ើបសួរ។ ករណីបែបនេះច្បាប់មិនបានកំណត់ថាឲ្យសភាស៊ើបសួរត្រូវធ្វើសេចក្តីសម្រេចក្នុងរយៈពេលប៉ុន្មាននោះទេ លើកលែងតែរឿងឃុំខ្លួនរបស់សភាស៊ើបសួរមានរយៈពេលតែ១៥(ដប់ប្រាំ)ថ្ងៃ[57]។ ក៏ប៉ុន្តែជាការប្រសើរសាលាឧទ្ធរណ៍ប្រហែលជាគួរឆ្លើយតបវិញឲ្យបានឆាប់រហ័សតាមដែលអាចធ្វើបានដើម្បីឲ្យជនជាប់ចោទបានមានសេរីភាពឡើងវិញបានលឿន។

ករណីទី២៖ចៅក្រមស៊ើបសួរទទួលបណ្តឹងអំពីអង្គហេតុដែលមាននៅក្នុងដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួររបស់ព្រះរាជអាជ្ញា។ ចៅក្រមស៊ើបសួរត្រូវស៊ើបសួរតែអំពីអង្គហេតុនោះតែប៉ុណ្ណោះ។ ប្រសិនបើមានលេចនូវអង្គហេតុថ្មីដែលអាចជាបទល្មើសព្រហ្មទណ្ឌនៅក្នុងពេលស៊ើបសួរចៅក្រមស៊ើបសួរត្រូវជូនដំណឹងអំពីអង្គហេតុថ្មីនេះទៅព្រះរាជអាជ្ញាភ្លាម។

ព្រះរាជអាជ្ញា អាចប្តឹងសុំឲ្យចៅក្រមស៊ើបសួរធ្វើការស៊ើបសួរលើអង្គហេតុថ្មីនេះបានតាមរយៈដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរបន្ថែម។ បើគ្មានដីកាបញ្ជូនរឿងឲ្យស៊ើបសួរបន្ថែមចៅក្រមស៊ើបសួរគ្មានអំណាចស៊ើបសួរទៅលើអង្គហេតុថ្មីនោះបានឡើយ។ ក៏ប៉ុន្តែចៅក្រមស៊ើបសួរមិនចាំបាច់សុំដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរបន្ថែមទេប្រសិនបើអង្គហេតុថ្មីនោះជាស្ថានទម្ងន់ទោសទៅលើអង្គហេតុដែលចែងនៅក្នុងដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរដំបូង[58]។

ករណីទី៣៖ក្នុងករណីដែលព្រះរាជអាជ្ញាយល់ស្របនឹងដីកាលើកលែងការចោទប្រកាន់របស់ចៅក្រមស៊ើបសួរនោះជនជាប់ចោទត្រូវតែដោះលែង ប្រសិនបើជនជាប់ចោទនោះគ្មានជាប់ទាក់ទិនទៅនឹងការឃុំខ្លួនដោយមូលហេតុអ្វីផ្សេងទៀតក្រៅពីការចោទប្រកាន់របស់ព្រះរាជ

[56] មាត្រា២៧០ ក្រមនីតិវិធីព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជាឆ្នាំ២០០៧

[57] មាត្រា២៧៨ ក្រមនីតិវិធីព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជាឆ្នាំ២០០៧

[58] មាត្រា១២៥ ក្រមនីតិវិធីព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជាឆ្នាំ២០០៧

អាជ្ញាទេនោះ។ ប្រសិនបើសភាស៊ើបសួរបដិសេធចោលដីកាលើកលែងការចោទប្រកាន់ជនជាប់ចោទនឹងត្រូវចាប់ឃុំខ្លួនជាបណ្ដោះអាសន្នជាថ្មី (បើជនជាប់ចោទត្រូវបានឃុំខ្លួនរួចមកត្រូវបានដោះលែង)។ ចៅក្រមស៊ើបសួរមានកាតព្វកិច្ចត្រូវតែគោរពសាលដីការបស់សភាស៊ើបសួរ។

ករណីទី៤៖ ប្រសិនបើចៅក្រមស៊ើបសួរយល់ឃើញថាសំណុំរឿងនោះមិនស្ថិតនៅក្រោមសមត្ថកិច្ចរបស់ខ្លួនទេនោះ ចៅក្រមស៊ើបសួរត្រូវបង្គាប់ឲ្យបង្វិលសំណុំរឿងជូនទៅព្រះរាអាជ្ញាវិញ ដើម្បីឲ្យព្រះរាជអាជ្ញាបញ្ជូនសំណុំរឿងនេះជូនទៅតុលាការដែលមានសមត្ថកិច្ចតាមដែនដី។

ករណីទី៥៖ ប្រសិនបើជនដែលប្រព្រឹត្តអំពើនោះនៅតែគេមិនស្គាល់ ចៅក្រមស៊ើបសួរត្រូវចេញដីកាលើកលែងការចោទប្រកាន់ ។

ចៅក្រមស៊ើបសួរអាចដោះលែងជនត្រូវចោទឲ្យមានសេរីភាពឡើងវិញ និងលើកលែងការចោទប្រកាន់បានផងដែរ ក្នុងដំណាក់កាលស៊ើបសួរនោះ។ ហេតុដូចនេះចៅក្រមស៊ើបសួរអាចចេញដីកាលើកលែងការចោទប្រកាន់ក្នុងករណី៖

១. អំពើប្រព្រឹត្តមិនមែនជាបទឧក្រិដ្ឋ បទមជ្ឈិម ឬបទលហុ

២. ជនដែលប្រព្រឹត្តអំពើនោះនៅតែគេមិនស្គាល់

៣. គ្មានភស្តុតាងដាក់បន្ទុកគ្រប់គ្រាន់លើជនត្រូវចោទ។

**កថាខណ្ឌទី២៖ ការសម្រេចដោយដីកាដំណោះស្រាយ**

នៅក្នុងដីកាដំណោះស្រាយចៅក្រមស៊ើបសួរត្រូវសម្រេចអំពីការប្រគល់ទៅឲ្យម្ចាស់ដើមវិញនូវវត្ថុដែលបានចាប់យក[59]។

គេសង្កេតឃើញថាបើចេញដីកាដំណោះស្រាយនោះត្រូវបញ្ចប់ការឃុំខ្លួនបណ្ដោះអាសន្ន និងដីកាសម្រេចដាក់ឲ្យស្ថិតនៅក្រោមការត្រួតពិនិត្យតាមផ្លូវតុលាការ។

នៅគ្រប់ដីកាដំណោះស្រាយទាំងអស់របស់ចៅក្រមស៊ើបសួរត្រូវធ្វើជាលាយលក្ខណ៍អក្សរចុះកាលបរិច្ឆេទ និងមានចុះហត្ថលេខារបស់ចៅក្រមស៊ើបសួរ និងក្រឡាបញ្ជី។ នៅក្នុងដីកាដំណោះស្រាយមានចែងនូវធាតុផ្សេងៗនៃជនត្រូវចោទដូចជា គោត្តនាម នាម ទីកន្លែង និង ថ្ងៃ ខែ ឆ្នាំកំណើត លំនៅឋាន និងមុខរបររបស់ជននោះ។ មិនតែប៉ុណ្ណោះដីកាដំណោះស្រាយចង្អុលបង្ហាញបទល្មើសដែលច្បាប់កំណត់ និងដាក់បន្ទុកលើជនត្រូវចោទរួមជាមួយមូលហេតុដែលមាន ឬគ្មានបន្ទុកគ្រប់គ្រាន់ប្រឆាំងនឹងបុគ្គលនោះ។

[59] មាត្រា២៤៨ ក្រមនីតិវិធីព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជាឆ្នាំ២០០៧

ដីកាដំណោះស្រាយធ្វើឲ្យមានការប្រគល់នូវវត្ថុដែលបានចាប់យកនៅក្នុងដំណាក់កាលស៊ើបសួរដែលក្នុងនោះមានដូចជា អាវុធដែលចាប់យកក្នុងលក្ខខ័ណ្ឌដែលអាវុធនោះមិនបានប្រើប្រាស់សម្រាប់ប្រព្រឹត្តបទល្មើស និងប្រាក់ធានាដែលជនត្រូវចោទបានបង់ (ប្រសិនបើមាន)។

ដីកាដំណោះស្រាយដែលចូលជាស្ថាពរ មានអានុភាពលុបបំបាត់ចោលពីសំណុំរឿងនូវគ្រប់មោឃភាពទាំងអស់ដែលអាចកើតមានចំពោះសំណុំរឿង[60]។

ក្រោយពេលទទួលបាននូវសេចក្តីសន្និដ្ឋានស្ថាពរពីអយ្យការហើយចៅក្រមស៊ើបសួរធ្វើចំណាត់ការលើសំណុំរឿងដោយធ្វើការសម្រេចមួយតាមរយៈ ដីកាដំណោះស្រាយ ។

### ក. ការលើកលែងការចោទប្រកាន់

ប្រសិនបើចៅក្រមស៊ើបសួរយល់ឃើញថាអង្គហេតុដែលមាននៅក្នុងសំណុំរឿងមិនចូលជាបទល្មើសឧក្រិដ្ឋ មជ្ឈិម ឬបទលហុ ឬជនប្រព្រឹត្តអំពើនៅតែគេមិនស្គាល់ ឬប្រសិនបើមានបន្ទុកគ្រប់គ្រាន់ដែលបញ្ជាក់ថាជនជាប់ចោទមិនមានពិរុទ្ធភាពនោះ ចៅក្រមស៊ើបសួរអាចសម្រេចធ្វើការលើកលែងចោទប្រកាន់បាន។ ការសម្រេចលើកលែងការចោទប្រកាន់នេះ មានថែងមូលហេតុច្បាស់លាស់និងជូនដំណឹងទៅភាគីទាំងអស់ដើម្បីអាចឲ្យភាគីដែលមិនសុខចិត្តនឹងការសម្រេចនោះធ្វើការតវ៉ានៅសភាស៊ើបសួរ។ លើសពីនេះទៅទៀត ចៅក្រមស៊ើបសួរអាចចេញដីកាលើកលែងចោទប្រកាន់ក្នុងករណីរលត់បណ្តឹងអាជ្ញា ផុតអាជ្ញាយុកាល ឬមរណភាពនៃចារីជាដើម។

សេចក្តីសម្រេចលើកលែងការចោទប្រកាន់មិនរលត់បណ្តឹងអាជ្ញាទេ ព្រោះប្រសិនបើការលើកលែងចោទប្រកាន់មានមូលហេតុមកពីអវត្តមាននៃបន្ទុកគ្រប់គ្រាន់ប្រឆាំងនឹងជនត្រូវចោទ ឬមកពីពុំមានចារី ដូច្នេះប្រសិនបើមានបន្ទុកថ្មីលេចឡើងព្រះរាជអាជ្ញាអាចអនុញ្ញាតឲ្យចៅក្រមស៊ើបសួរបើកការស៊ើបសួរទៅលើអង្គហេតុនោះជាថ្មីម្តងទៀត។ ហេតុដូច្នេះដើមបណ្តឹងរដ្ឋប្បវេណីដែលមិនសុខចិត្តនឹងសេចក្តីសម្រេចលើកលែងចោទប្រកាន់អាចប្តឹងទៅឧទ្ធរណ៍ចំពោះដីកាលើកលែងការចោទប្រកាន់នេះបាន ដោយគ្រាន់តែប្តឹងនៅការិយាល័យក្រឡាបញ្ជីនៃសភាស៊ើបសួរ ។

### ខ. ការបញ្ជូនខ្លួនជនជាប់ចោទទៅជំនុំជម្រះ

ប្រសិនបើចៅក្រមស៊ើបសួរយល់ឃើញថាមានបន្ទុកគ្រប់គ្រាន់ដើម្បីធ្វើការចោទប្រកាន់ជនជាប់ចោទពីបទល្មើសព្រហ្មទណ្ឌ ចៅក្រមស៊ើបសួរបញ្ជូនសំណុំរឿង និងជនជាប់ចោទទៅជំនុំជម្រះ។ ដីកាបញ្ជូនទៅជំនុំជម្រះអាចជាអំពើទាំងអស់ ឬមួយផ្នែកនៃសំណុំរឿងមានន័យថាអាចអំពីខ្លះធ្វើការលើកលែងការចោទប្រកាន់ ហើយអំពីខ្លះទៀតជាកម្មវត្ថុនៃការចោទប្រកាន់។ នៅពេលដែលចៅក្រមស៊ើបសួរសម្រេចបញ្ជូនរឿងទៅជំនុំជម្រះចៅក្រមស៊ើបសួរត្រូវបញ្ជូនសំណុំរឿង

[60] មាត្រា២៥៦ ក្រមនីតិវិធីព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជាឆ្នាំ២០០៧

និងភស្តុតាងដែលមានទៅប្រធានតុលាការដើម្បីកំណត់សវនាការជំនុំជម្រះ។ ចៅក្រមស៊ើបសួរអាចរក្សាជនជាប់ចោទ ឲ្យនៅជាប់ឃុំជាបណ្តោះអាសន្ន ដែលសម្រេចដោយដីកាដំណោះស្រាយរហូតដល់ចប់ចូលបង្ហាញខ្លួននៅចំពោះមុខតុលាការ ប្រសិនបើជនជាប់ចោទនោះនៅជាប់ឃុំជាបណ្តោះអាសន្ន។ នៅក្នុងដីកាបញ្ជូនរឿងទៅជំនុំជម្រះត្រូវរៀបរាប់អំពីអំពើដែលត្រូវចោទប្រកាន់ និងឈ្មោះបទល្មើសតាមកំណត់ច្បាប់ជាធរមាន ។

# ជំពូកទី៣

# ដំណើរការជំនុំជម្រះ

## ផ្នែកទី១៖ នីតិវិធីនៃការរៀបចំ

### កថាខណ្ឌទី១៖ ការរៀបចំតុលាការ

នៅពេលដែលប្រធានតុលាការបានទទួលសំណុំរឿងព្រហ្មទណ្ឌពីតំណាងអយ្យការតាមនីតិវិធីនៃការបញ្ជូនរឿងទៅជំនុំជម្រះដោយផ្ទាល់ ឬកំណត់ហេតុស្តីពីការបង្គាប់នាំចូលបង្ហាញខ្លួនភ្លាម ឬពីចៅក្រមស៊ើបសួរតាមរយៈដីកាបញ្ជូនរឿងទៅជំនុំជម្រះ ឬពីសភាស៊ើបសួរ ប្រធានតុលាការត្រូវចាត់តាំងចៅក្រមអាសនៈណាម្នាក់ ឬបីនាក់តាមករណីរឿងក្តីមជ្ឈិម ឬបទឧក្រិដ្ឋ ដើម្បីទទួលបន្ទុកធ្វើការជំនុំជម្រះដែលចៅក្រមអាសនៈនេះអាចជាប្រធានតុលាការខ្លួនឯងផ្ទាល់ ឬចៅក្រមអាសនៈមួយផ្សេងទៀតក្រៅពីចៅក្រមដែលធ្វើការស៊ើបសួរ។ សាលាដំបូងបើកការជំនុំជម្រះដោយមានចៅក្រម១រូប និងមានក្រឡាបញ្ជី១រូប។

#### ក. ការដកខ្លួនដោយឯកឯង

ចៅក្រមដែលមានមូលហេតុត្រឹមត្រូវនៃការដកខ្លួនមិនព្រមចូលខ្លួនក្នុងការជំនុំជម្រះរឿងក្តីណាមួយនោះអាចស្នើសុំឲ្យគេជំនួសខ្លួនបាន។ ពាក្យសុំដកខ្លួននេះត្រូវដាក់ជូនទៅតុលាការរបស់ខ្លួន។ ប្រសិនបើយល់ឃើញថាមានមូលហេតុត្រឹមត្រូវប្រធានតុលាការចាត់ចៅក្រមផ្សេងជំនួសចៅក្រមនេះ ហើយសេចក្តីសម្រេចនេះមិនអាចតវ៉ាបានឡើយ។

ជាធម្មតាក្នុងដំណើររឿងក្តីចំពោះមុខតុលាការអាចមានឧប្បត្តិហេតុកើតឡើងទាក់ទងនឹងការចាត់តាំងចៅក្រមអាសនៈដែលជាមូលហេតុនាំឲ្យកើតមាននូវបណ្តឹងជិតចិត្ត និងអាចកើតមាននូវបណ្តឹងសុំបដិសេធផងដែរ។

#### ខ. បណ្តឹងជិតចិត្ត

បណ្តឹងជិតចិត្ត គឺជាបណ្តឹងដែលបើកឲ្យភាគីណាមួយធ្វើការប្តឹងតែចៅក្រមអាសនៈណាដែលខកខានដោយចេតនាមិនបានបំពេញករណីយកិច្ចចំពោះវិជ្ជាជីវៈរបស់ខ្លួនឲ្យបានត្រឹមត្រូវ ឬបំពានដោយរំលោភលើក្រមសីលធម៌របស់តុលាការដូចជា៖

- កាលណាចៅក្រម ឬសហព័ទ្ធរបស់ចៅក្រម ឬអតីតសហព័ទ្ធរបស់ចៅក្រមជាភាគីណាមួយក្នុងរឿងក្តី
- កាលណាចៅក្រមជាញាតិលោហិតរហូតដល់ថ្នាក់ទី៦ ឬញាតិពន្ធរហូតដល់ថ្នាក់ទី៣ ឬអតីតញាតិពន្ធរហូតដល់ថ្នាក់ទី៣ របស់ភាគីណាមួយ
- កាលណាចៅក្រមជាអ្នកអាណាព្យាបាលរបស់ភាគីណាមួយ

- កាលណាដែលចៅក្រមទទួលបន្ទុករឿងក្តីធ្លាប់ ឬកំពុងមានវិវាទនៅតុលាការជាមួយភាគីណាមួយ
- កាលណាចៅក្រមបានធ្វើជាសាក្សី ឬជាអ្នកជំនាញក្នុងរឿងក្តី
- កាលណាចៅក្រមធ្លាប់ជាអ្នកតំណាង ឬអ្នកជំនួយឲ្យភាគីចំពោះរឿងក្តី
- កាលណាចៅក្រមបានចូលរួមក្នុងការសម្រេចសេចក្តីក្នុងនាមជាមជ្ឈត្តករចំពោះរឿងក្តី ឬបានចូលរួមក្នុងការសម្រេចសេចក្តីនៅសាលាដំបូងដែលបានប្តឹងឧបាស្រ័យ ឬការជំនុំជម្រះនៃបណ្តឹងឧទ្ធរណ៍ដែលបានឧបាស្រ័យ ឬបង្ហាញមតិយោបល់លើផ្នែកច្បាប់ចំពោះរឿងក្តី[61]។

ហេតុដូចនេះភាគីដែលបានប្តឹងជិតចិត្តចៅក្រមអាសនៈណាមួយ ត្រូវតែជូនពាក្យប្តឹងតាំងពីខ្លួនបានដឹងពីមូលហេតុនៃការប្តឹងជិតចិត្ត។ ពាក្យប្តឹងត្រូវតែចង្អុលឲ្យបានច្បាស់លាស់អំពីមូលហេតុនៃការប្តឹងជិតចិត្ត ហើយត្រូវមានភស្តុតាងបញ្ជាក់ឱ្យបានច្បាស់លាស់ បើពុំដូច្នេះទេមិនអាចទទួលបានឡើយ។ ក្នុងករណីណាក៏ដោយពាក្យបណ្តឹងជិតចិត្តចៅក្រមមិនអាចធ្វើបានឡើយនៅក្រោយពេលបិទការពិភាក្សាដេញដោល។

ចំពោះបណ្តឹងជិតចិត្តដែលទាក់ទងនឹងប្រធានសាលាដំបូង ឬចៅក្រមសាលាដំបូងត្រូវសម្រេចដោយប្រធានសាលាឧទ្ធរណ៍[62]។

### កថាខណ្ឌទី២ ៖ ការរៀបចំសវនាការជំនុំជម្រះ

ការរៀបចំសវនាការ គឺជាដំណើរការមួយក្នុងវិស័យតុលាការ ហើយការរៀបចំនេះក្នុងគោលបំណងដើម្បីធ្វើការកោះហៅគ្រប់ភាគីដែលពាក់ព័ន្ធឲ្យបានដឹង និងដើម្បីធ្វើការជំនុំជម្រះលើសំណុំរឿង។

ការរៀបចំសវនាការ ក៏ជាការចាត់តាំងចៅក្រមអាសនៈទទួលយកសំណុំរឿងដើម្បីធ្វើចំណាត់ការបន្ត។ ក្នុងន័យនេះការរៀបចំសវនាការមានគោលដៅចង់ឲ្យយុត្តាធិការជំនុំជម្រះធ្វើ ការវិនិច្ឆ័យទៅលើសំណុំរឿង រួមទាំងជនជាប់ចោទដែលបានបញ្ជូនមកពីព្រះរាជអាជ្ញា ឬចៅក្រមស៊ើបសួរ។

ម្យ៉ាងវិញទៀត អ្នកដែលចូលរួមក្នុងសវនាការទាំងអស់ត្រូវតែគោរពតាមបទបញ្ជាផ្ទៃក្នុងរបស់សវនាការជំនុំជម្រះឲ្យបានត្រឹមត្រូវ ដើម្បីជៀសវាងភាពអសន្តិសុខនៅពេលសវនាការ។

#### ក. បទបញ្ជា[63]

នៅក្នុងសវនាការជំនុំជម្រះរឿងក្តីព្រហ្មទណ្ឌដើម្បីឲ្យមានសណ្តាប់ធ្នាប់ សវនាការត្រូវមានបទបញ្ជាដែលបុគ្គលគ្រប់រូបត្រូវគោរព និងអនុវត្តជាដាច់ខាតនាពេលសវនាការ។ បទបញ្ជាត្រូវបាន

[61] មាត្រា៥៥៦ ក្រមនីតិវិធីព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជាឆ្នាំ២០០៧

[62] មាត្រា៥៥៨ ក្រមនីតិវិធីព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជាឆ្នាំ២០០៧

[63] ឧបសម្ព័ន្ធ

បិទនៅបន្ទប់សវនាការ និងមុនពេលជំនុំជម្រះក្រឡាបញ្ជីបានអានដើម្បីឲ្យសាធារណៈជន ដើមបណ្តឹង សាក្សី និងជនជាប់ចោទបានស្តាប់។

បទបញ្ជាផ្ទៃក្នុងរបស់សវនាការតម្រូវឲ្យអ្នកដែលចូលរួមត្រូវគោរពលក្ខខណ្ឌមួយចំនួនដែលបានកំណត់ក្នុងបទបញ្ជា ហើយប្រសិនបើបុគ្គលណាដែលមិនគោរពតាមបទបញ្ជានេះទេ និងត្រូវព្រមានដេញចេញពីសវនាការ ឬទទួលការផ្តន្ទាទោសតាមច្បាប់ផងដែរប្រសិនបើជាបទល្មើស។

**ខ. នីតិវិធីនៃការជំនុំជម្រះ**

❖ **មុនពេលសវនាការ**

ប្រធានតុលាការជាអ្នកកំណត់កាលបរិច្ឆេទនៃសវនាការ លើកលែងតែករណីនៃនីតិវិធីចូលបង្ហាញខ្លួនភ្លាម។ ក្នុងការកំណត់កាលបរិច្ឆេទនេះ ប្រធានតុលាការត្រូវគោរពតាមរយៈច្បាប់ដែលមានចែងក្នុងមាត្រា៤៥៧ និង៤៦៦ នៃក្រមនីតិវិធីព្រហ្មទណ្ឌ។

ការកោះហៅជនជាប់ចោទ ដើមបណ្តឹងរដ្ឋប្បវេណី ជនរងគ្រោះ សាក្សី អ្នកជំនាញ អ្នកបកប្រែ អ្នកទទួលខុសត្រូវរដ្ឋប្បវេណី ធ្វើដោយព្រះរាជអាជ្ញាដែលមានចែងក្នុងមាត្រា២៩៤ មាត្រា២៩៥ និងមាត្រា២៩៦ នៃក្រមនីតិវិធីព្រហ្មទណ្ឌ។ ក្នុងករណីដែលតុលាការទទួលបណ្តឹងដោយដីកាបញ្ជូនរបស់ចៅក្រមស៊ើបសួរ ឬសាលដីកាបញ្ជូនរបស់សភាស៊ើបសួរ លិខិតចម្លងដីកាបញ្ជូន ឬសាលដីកាបញ្ជូនត្រូវភ្ជាប់ជាមួយនឹងដីកាកោះហៅដើម្បីប្រគល់ឲ្យជនជាប់ចោទ។ ប្រសិនបើមេធាវី ព្រះរាជអាជ្ញា ក៏ត្រូវកោះហៅមេធាវីផងដែរ។ មេធាវីអាចពិនិត្យមើលសំណុំរឿងនៅការិយាល័យក្រឡាបញ្ជីនៃតុលាការនៅក្រោមការត្រួតពិនិត្យរបស់ក្រឡាបញ្ជី[64] ។

❖ **នាពេលសវនាការ**

មុននឹងចាប់ផ្តើមសវនាការក្រឡាបញ្ជីត្រូវផ្ទៀងផ្ទាត់ពីអវត្តមានរបស់ជនជាប់ចោទ ដើមបណ្តឹងរដ្ឋប្បវេណី ជនរងគ្រោះ សាក្សី អ្នកទទួលខុសត្រូវរដ្ឋប្បវេណី ដើម្បីរាយការណ៍ជូនតុលាការ ។

ក្រឡាបញ្ជីមានពេលប្រាំនាទីដើម្បីអានបទប្បញ្ញត្តិរបស់តុលាការមុននឹងចាប់ផ្តើមធ្វើការជំនុំជម្រះ។ បន្ទាប់ពីក្រឡាបញ្ជីអានបទបញ្ញត្តិតុលាការចប់ហើយ ក្រឡាបញ្ជីត្រូវទៅអញ្ជើញចៅក្រមជំនុំជម្រះពីបន្ទប់។ ពេលចៅក្រមចូលក្នុងបន្ទប់សវនាការ ក្រឡាបញ្ជីបន្លឺថា តុលាការ ហើយបន្ទាប់មកមនុស្សទាំងអស់ក្រោកឈរជាសញ្ញាគោរពអង្គតុលាការ។ ចៅក្រមបង្ហាញពីសមាសភាពដោយប្រាប់ពីខ្លួនឯង ក្រឡាបញ្ជីជំនុំជម្រះ ព្រះរាជអាជ្ញា សំណុំរឿងដែលត្រូវជំនុំជម្រះ សាក្សី ជនជាប់ចោទ និងមេធាវីការពារជនជាប់ចោទ។ ប្រសិនបើជាជនជាប់ចោទគ្មានមេធាវីការពារទេ ចៅក្រមអាច

[64] មាត្រា១៩ ក្រមនីតិវិធីព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជាឆ្នាំ២០០៧

សួរជនជាប់ចោទថាចង់បានមេធាវីការពារ ឬយ៉ាងណា។ បើជនជាប់ចោទត្រូវការមេធាវីនោះចៅក្រម អាចតែងតាំងមេធាវីឲ្យបាន។

នៅពេលចាប់ផ្តើមបើកការជំនុំជម្រះ ចៅក្រមសួរបញ្ជាក់អត្តសញ្ញាណជនជាប់ចោទដូចជា ឈ្មោះ ឈ្មោះហៅក្រៅ អាយុ ទីកន្លែងកំណើត ទីលំនៅមុនពេលចាប់ខ្លួន កម្រិតវប្បធម៌ មុខរបរ ឈ្មោះសហព័ទ្ធ ចំនួនកូន ឈ្មោះឪពុកម្តាយ និងបទល្មើសដែលបានប្រព្រឹត្តពីមុន។ បន្ទាប់មកចៅក្រមប្រាប់ជនជាប់ចោទអំពីកាតព្វកិច្ចត្រូវនិយាយការពិតដែលទាក់ទងនឹងបទល្មើសដែលបានចោទ រួមទាំងសិទ្ធិដើម្បីទទួលបានមេធាវីការពារ និងសិទ្ធិថ្លែងសំដីចុងក្រោយក៏ត្រូវបានប្រាប់ឲ្យដឹងនៅពេលនោះដែរ។

បន្ទាប់មកចៅក្រមក៏សួរបញ្ជាក់អត្តសញ្ញាណ និងកាតព្វកិច្ចរបស់ជនរងគ្រោះដូចគ្នានឹងជនជាប់ចោទដែរ។ បើជនរងគ្រោះមានអ្នកតំណាង ចៅក្រមត្រូវសួរដូចគ្នាព្រមទាំងសួរបញ្ជាក់ពីទំនាក់ទំនងរវាងជនរងគ្រោះ និងអ្នកតំណាង។ ចៅក្រមត្រូវបញ្ជាក់ប្រាប់ជនរងគ្រោះពីសិទ្ធិរបស់គេដើម្បីបង្ហាញភស្តុតាង សិទ្ធិធ្វើសំណូមពរ និងសិទ្ធិរកមេធាវីមកតំណាង។ តមកទៀតចៅក្រមសួរបញ្ជាក់អត្តសញ្ញាណរបស់សាក្សី និងករណីកិច្ចរបស់គេគឺត្រូវនិយាយការពិត។

ចៅក្រមជំនុំជម្រះសួរទៅព្រះរាជអាជ្ញាថា តើបទចោទប្រកាន់នោះមានផ្លាស់ប្តូរដែរឬទេ? ប្រសិនបើគ្មានផ្លាស់ប្តូរអ្វីទេ នោះចៅក្រមសុំឲ្យព្រះរាជអាជ្ញាអានបទចោទប្រកាន់។ បន្ទាប់មកចៅក្រមជំនុំជម្រះសុំឲ្យនគរបាលយុត្តិធម៌អានរបាយការណ៍របស់នគរបាលយុត្តិធម៌ របាយការណ៍របស់ចៅក្រមស៊ើបសួរ និងចម្លើយរបស់សាក្សី។

ចៅក្រមក៏ចាប់ផ្តើមសួរទៅជនជាប់ចោទ តើខ្លួនពិតជាបានប្រព្រឹត្តល្មើសដូចដែលព្រះរាជអាជ្ញាបានចោទប្រកាន់ដែរឬទេ? និងអំពីដំណើររឿងដែលគេចោទថាបានប្រព្រឹត្តបទល្មើស។ ជនជាប់ចោទអាចឆ្លើយទទួលពិរុទ្ធភាព ឬមិនទទួលយកបទចោទប្រកាន់។ បើសិនជនជាប់ចោទមិនឆ្លើយទទួលពិរុទ្ធភាពទេនោះ ចៅក្រមនឹងហៅព្រះរាជអាជ្ញា មេធាវីការពារជនរងគ្រោះ និងមេធាវីការពារជនជាប់ចោទឲ្យសួរសំណួរជនជាប់ចោទ។ បន្ទាប់ពីសួរសំណួរជនជាប់ចោទរួចមក ចៅក្រមឲ្យជនរងគ្រោះពិពណ៌នាអំពីរឿងហេតុដែលខ្លួនទទួលរង ក្រោយមកព្រះរាជអាជ្ញា មេធាវីការពារជនរងគ្រោះ និងមេធាវីការពារជនជាប់ចោទ សួរជនរងគ្រោះ។ ចៅក្រមកោះហៅសាក្សីដាក់បន្ទុក និងសាក្សីដោះបន្ទុកមកសួរយកចម្លើយជាបន្តបន្ទាប់គ្នា។

ចំពោះសំណួររបស់ចៅក្រម ភាគីផ្សេងអាចតាំងសំណួរបន្ថែមទៅលើសំណួររបស់ចៅក្រមបានតែត្រូវសួរតាមរយៈចៅក្រម។ ព្រះរាជអាជ្ញា ឬមេធាវីជនជាប់ចោទអាចសួរ ដោយផ្ទាល់តែម្តងទៅ ជនជាប់ចោទ ឬសាក្សី បន្ទាប់ពីបានការយល់ព្រមពីចៅក្រម។ បន្ទាប់ពីបានស្នើសុំទៅចៅក្រមហើយមេធាវីជនជាប់ចោទឡើងថ្លែងការពារជនជាប់ចោទ ដោយផ្តល់ភស្តុតាង ហៅសាក្សីមកផ្ទាញ់

សាក្សីដាក់បន្ទុក និងដោយជំទាស់នឹងពាក្យចោទប្រកាន់។ នៅចំនុចនេះប្រសិនបើចាំបាច់ចៅក្រម អាចស្នើសុំឲ្យសាក្សី និងជនជាប់ចោទសួរតទល់គ្នា។

ព្រះរាជអាជ្ញា ដើមបណ្ដឹងរដ្ឋប្បវេណី និងជនជាប់ចោទ ឬមេធាវីការពារជនជាប់ចោទមានសិទ្ធិលើកអញ្ញត្រកម្មមួយមកដោះស្រាយ។ ប៉ុន្តែអញ្ញត្រកម្មត្រូវតែលើកឡើងមុនជំណាក់កាលការពារដល់អង្គសេចក្ដីបើពុំដូច្នេះទេមិនអាចទទួលយកបានឡើយ[65]។ អញ្ញត្រកម្មជាមធ្យោបាយមួយដែលភាគីលើកឡើងដើម្បីទាមទារឲ្យចៅក្រមពិនិត្យមើលសំអាងរបស់ភាគីម្ខាងទៀត ពិនិត្យមើលអសមត្ថកិច្ចរបស់តុលាការ ឬភាពមិនប្រក្រតីនៃនីតិវិធីជាដើម។ តុលាការត្រូវសម្រេចអំពីអញ្ញត្រកម្មតាមសាលក្រមមួយដាច់ដោយឡែកពីសាលក្រមនៃអង្គសេចក្ដី។ ប៉ុន្តែតុលាការអាចបញ្ចូលឧប្បត្តិហេតុទៅនឹងអង្គសេចក្ដី ហើយសម្រេចដោយសាលក្រមមួយដូចគ្នាអំពីអញ្ញត្រកម្មជាមួយនឹងអង្គសេចក្ដី[66]។ អញ្ញត្រកម្មដែលលើកឡើងនៅក្នុងកំឡុងពេលជំនុំជម្រះត្រូវបានសម្រេចដោយសាលក្រមមួយហៅថាសាលក្រមចាត់របៀប។

ប្រសិនបើគ្មានបញ្ហាខាងលើនេះ ចៅក្រមបន្ទាប់ពីស្ដាប់ភាគី និងសាក្សីទាំងសងខាងហើយ សុំឲ្យភាគីទាំងអស់ធ្វើសេចក្ដីសន្និដ្ឋានចុងក្រោយ បើសិនជាមានភស្តុតាងគ្រប់គ្រាន់។ ជាដំបូងព្រះរាជអាជ្ញាធ្វើសេចក្ដីសន្និដ្ឋានអំពីទោស ទណ្ឌកម្ម បន្ទាប់មកមេធាវីការពារក្ដីរបស់ជនជាប់ចោទធ្វើសេចក្ដីសន្និដ្ឋានចុងក្រោយ។

❖ **ពេលបញ្ចប់សវនាការ**

បើគ្មានការជជែកពិភាក្សាដេញដោល ឬតាំងសំណួរអ្វីផ្សេងទៀតនោះទេ ចៅក្រមចូលក្នុងបន្ទប់ពិភាក្សាចំនួនប្រមាណ ១៥ ទៅ ៣០ នាទី ដើម្បីសរសេរសាលក្រមផ្អែកសំអាង និង សេចក្ដីសម្រេច។ បន្ទាប់ពីពិចារណារួចហើយ ចៅក្រមជំនុំជម្រះចេញមកប្រកាសសាលក្រមជាសាធារណៈតាងនាមប្រជារាស្ត្រខ្មែរ។ ចៅក្រមអាចលើកសវនាការទៅ ធ្វើនៅថ្ងៃក្រោយទៀតបាន។ គួរកត់សម្គាល់ថា ពេលចូលក្នុងបន្ទប់ពិចារណាហើយចៅក្រមជំនុំជម្រះមិនទទួលយកចម្លើយ ឬភស្តុតាងណាទៀតឡើយ។ ការសម្រេចសេចក្ដីនៅសាលាដំបូងប្រសិនបើចៅក្រមត្រូវសម្រេចជាក្រុម បើមិនមានមតិឯកច្ឆ័ន្ទទេ ការសម្រេចសេចក្ដីត្រូវសម្រេចដោយមតិភាគច្រើនគឺ ២\៣ (ពីរភាគបី)។ បើចៅក្រមណាជំទាស់ចៅក្រមនោះអាចធ្វើកំណត់ហេតុស្ដីពីមតិជំទាស់ដោយមានចុះហត្ថលេខារបស់ចៅក្រមទាំងអស់។ នៅពេលដែលចៅក្រមសរសេរសាលក្រមដែលមានសេចក្ដីពេញលេញដោយមានចុះហត្ថលេខារបស់ចៅក្រម និងក្រឡាបញ្ជីផងនោះគេហៅថា មូលសាលក្រម ឬសាធិកសាលក្រម។ សេចក្ដីចម្លងពីមូលសាលក្រមដែលមានសេចក្ដីបញ្ជាក់របស់ក្រឡាបញ្ជី និងប្រធានក្រុម

[65] មាត្រា៣៨៩ ក្រមនីតិវិធីព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជាឆ្នាំ២០០៧

[66] មាត្រា៣៩៦ ក្រមនីតិវិធីព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជាឆ្នាំ២០០៧

ប្រឹក្សាជំនុំជម្រះគេហៅថា អនុសារសាលក្រម ឬសេចក្តីចម្លងសាលក្រម។ ក្នុងរឿងក្តីព្រហ្មទណ្ឌក៏មានសម្រង់សាលក្រមផងដែរ ដែលជាការដកស្រង់តែសេចក្តីសម្រេចតែប៉ុណ្ណោះ។

## ផ្នែកទី២ ៖ សាលក្រម

### កថាខណ្ឌទី១ ៖ ប្រភេទនៃសាលក្រម

#### ក. សាលក្រមចំពោះមុខ

សាលក្រមចំពោះមុខ គឺជាសាលក្រមដែលចេញនៅចំពោះវត្តមានរបស់ភាគីនៃបណ្តឹងទាំងអស់។ ចំពោះសាលក្រមប្រភេទនេះ ពិរុទ្ធជន ដើមបណ្តឹងរដ្ឋប្បវេណី ឬអ្នកទទួលខុសត្រូវរដ្ឋប្បវេណី បើមិនសុខចិត្តអាចប្តឹងឧទ្ធរណ៍អំពីសាលក្រមនេះ ហើយត្រូវតែធ្វើក្នុងរយៈពេល១(មួយ) ខែ ផ្តើមគិតចាប់ពីពេលប្រកាសសាលក្រម។ កាលណាសាលក្រមនោះជាសាលក្រមចាត់ទុកថាចំពោះមុខ រយៈពេលប្តឹងឧទ្ធរណ៍ផ្តើមគិតចាប់ពីពេលដែលទទួលដំណឹងអំពីសាលក្រមនោះ ទោះបីការឲ្យដំណឹងនេះធ្វើតាមវិធីណាក៏ដោយសាលក្រមនេះគិតតែចំពោះពិរុទ្ធជនតែប៉ុណ្ណោះ[67]។ ព្រះរាជអាជ្ញាក៏អាចប្តឹងឧទ្ធរណ៍អំពីសាលក្រមនេះបានដែរ តែត្រូវធ្វើក្នុងរយៈពេល ១(មួយ) ខែ គិតចាប់ពីពេលដែលប្រកាសសាលក្រម[68]។

#### ខ. សាលក្រមចាត់ថាចំពោះមុខ

សាលក្រមដែលចាត់ថាចំពោះមុខ គឺជាសាលក្រមដែលចេញដោយអវត្តមានរបស់ជនជាប់ចោទ ប៉ុន្តែសាមីខ្លួនបានដឹងអំពីកាលបរិច្ឆេទនៃការជំនុំជម្រះផ្ទាល់ ឬបានដឹងអំពីការកោះហៅហើយនោះ សាលក្រមត្រូវចាត់ទុកថាសាលក្រមចំពោះមុខជនជាប់ចោទ។ សាលក្រមនេះ ត្រូវជូនដំណឹងទៅជនជាប់ចោទ[69]។

#### គ. សាលក្រមកំបាំងមុខ

សាលក្រមកំបាំងមុខ គឺជាសាលក្រមដែលចេញដោយអវត្តមានរបស់ជនជាប់ចោទ ដែលពុំបានដឹងពីការជំនុំជម្រះ។ ចំពោះសាលក្រមប្រភេទនេះ ពិរុទ្ធជនអាចធ្វើបណ្តឹងទាស់ក្នុងរយៈពេល ១៥(ដប់ប្រាំ) ថ្ងៃ ចាប់ផ្តើមគិតចាប់ពីថ្ងៃជូនដំណឹងអំពីសាលក្រមកំបាំងមុខកាលណាសាលក្រមនេះត្រូវប្រគល់ដល់ដៃពិរុទ្ធជនហើយនោះ ឬពីថ្ងៃដែលពិរុទ្ធជននោះបានដឹងយ៉ាងពិតប្រាកដអំពីសាលក្រមកាលណាសាលក្រមនេះ មិនបានប្រគល់ឲ្យដល់ពិរុទ្ធជនដោយផ្ទាល់ដៃទេ[70]។ ប្រសិនបើបណ្តឹងទាស់នេះមិនបានធ្វើទាន់ពេលវេលានោះទេ ពិរុទ្ធជននៅមានឱកាសប្តឹងឧទ្ធរណ៍បន្តទៀត។

---

67 មាត្រា៣៨២ ក្រមនីតិវិធីព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជាឆ្នាំ២០០៧

68 មាត្រា៣៨១ ក្រមនីតិវិធីព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជាឆ្នាំ២០០៧

69 មាត្រា៣៦១ ក្រមនីតិវិធីព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជាឆ្នាំ២០០៧

70 មាត្រា៣៦៨ ក្រមនីតិវិធីព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជាឆ្នាំ២០០៧

បណ្តឹងទាស់ត្រូវធ្វើដោយពាក្យប្តឹងជាលាយលក្ខណ៍អក្សរ ឬដោយផ្ទាល់មាត់នៅការិយាល័យក្រឡាបញ្ជីនៃតុលាការដែលបានប្រកាសសាលក្រម ឬនៅចំពោះមុខប្រធានពន្ធនាគារ ឬមណ្ឌលឃុំខ្លួន បើពិរុទ្ធជនកំពុងឃុំខ្លួនអាចដាក់ពាក្យមកតាមរយៈប៉ុស្តិ៍ប្រៃសណីយ៍ក៏បាន។ ពិរុទ្ធជនអាចរកមេធាវីដើម្បីឲ្យមកធ្វើជាតំណាងបាន ប៉ុន្តែមេធាវីត្រូវតែមានលិខិតអនុញ្ញាតឲ្យធ្វើបណ្តឹងទាស់។ ផ្ទុយទៅវិញ បើពិរុទ្ធជនជាអនីតិជនវិញ អាចត្រូវបានតំណាងដោយឪពុកម្តាយ ឬអាណាព្យាបាលផ្ទាល់តែម្តង ហើយក្នុងករណីនេះអ្នកតំណាងមិនចាំបាច់មានលិខិតប្រគល់សិទ្ធិទេ។

កាលណាបានទទួលពាក្យប្តឹងទាស់ ប្រធានពន្ធនាគារ ឬមណ្ឌលឃុំខ្លួន ឬប្រៃសនីយ៍ ត្រូវបញ្ជូនពាក្យបណ្តឹងទាស់នោះភ្លាមទៅក្រឡាបញ្ជីនៃតុលាការដែលបានប្រកាសសាលក្រម។ កាលណាអ្នកប្តឹងទាស់មិនចេះចុះហត្ថលេខាទេ អ្នកប្តឹងទាស់នេះត្រូវផ្តិតមេដៃ។

### ឃ. សាលក្រមរៀប ឬ សាលក្រមចាត់រៀប

តុលាការបង្គាប់ឲ្យប្រធានសវនាការ ចៅក្រមមួយរូបនៃក្រុមប្រឹក្សាជំនុំជម្រះ ឬចៅក្រមដទៃទៀតនៃតុលាការជាន់ដំបូងធ្វើការស៊ើបសួរបន្ថែម ប្រសិនបើយល់ឃើញថាការស្រាវជ្រាវថ្មីជាការចាំបាច់។ ចៅក្រមដែលទទួលបន្ទុកស៊ើបសួរបន្ថែមនេះ អាចប្រើសិទ្ធិអំណាចដូចជាចៅក្រមស៊ើបសួរដែរ[71]។

សាលក្រមចាត់របៀបមិនអាចប្តឹងឧទ្ធរណ៍តែឯងបានទេ មានន័យថាសាលក្រមចាត់របៀបអាចដាក់ជូនសាលាឧទ្ធរណ៍ពិនិត្យបាន លុះត្រាតែធ្វើព្រមគ្នាជាមួយនឹងសាលក្រមលើអង្គសេចក្តី ប៉ុន្តែសាលក្រមចាត់របៀបដែលបញ្ចប់នីតិវិធីអាចប្តឹងឧទ្ធរណ៍បាន[72]។

## កថាខណ្ឌទី២៖ អានុភាពនៃសាលក្រម

### ក. ខ្លឹមសារសាលក្រម

សាលក្រមណាក៏ដោយត្រូវតែមានសំអាងហេតុគ្រប់ចំណុចសំខាន់ៗនៃបទចោទប្រកាន់ និងគ្រប់ចំណុចនៃពាក្យសុំរបស់គូភាគី។ សំអាងហេតុត្រូវតែច្បាស់លាស់ មានន័យថាត្រូវបញ្ជាក់ឲ្យពិតប្រាកដនូវគំនិតរបស់ចៅក្រមដោយឥតនាំឲ្យមានការភ័ន្តច្រឡំ ឬសេចក្តីផ្ទុយគ្នានោះឡើយ។

សេចក្តីសម្រេចដែលជាផ្នែកសំខាន់បំផុតនៃសាលក្រមក៏ត្រូវតែសរសេរឲ្យបានច្បាស់លាស់ដូចសំអាងហេតុដែរ។ នៅក្នុងសេចក្តីសម្រេចត្រូវយោងមាត្រានៃអត្ថបទច្បាប់ទាំងឡាយដែលការសម្រេចត្រូវផ្អែកទៅលើ។

71 មាត្រា៣៣៩ ក្រមនីតិវិធីព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជាឆ្នាំ២០០៧

72 មាត្រា៣៨៥ ក្រមនីតិវិធីព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជាឆ្នាំ២០០៧

នៅក្នុងសាលក្រមត្រង់សេចក្តីសម្រេច បន្ទាប់ពីបានប្រកាសពិរុទ្ធភាពនៃជនជាប់ចោទ និងការទទួលខុសត្រូវរបស់អ្នកទទួលខុសត្រូវផ្នែករដ្ឋប្បវេណី សាលក្រមត្រូវកំណត់មូលទោស និងអនុទោស ប្រសិនបើមាន។

**ខ. ការប្រកាសសាលក្រម**

តុលាការដែលប្រកាសសាលក្រម ពុំមែនចេះតែប្រកាសនោះទេ គឺត្រូវតែគោរពទៅតាមគោលការណ៍នៃការប្រកាសសាលក្រម ដែលត្រូវបានកំណត់ឡើងដោយច្បាប់។ តុលាការក៏ត្រូវចេះពីរបៀបនៃការប្រកាសផងដែរ ដើម្បីឲ្យសាលក្រមមានអានុភាពគ្រប់គ្រាន់សម្រាប់អ្នកអនុវត្ត។

សាលក្រមរបស់តុលាការត្រូវតែប្រកាសជាសាធារណៈ ដែលនឹងត្រូវធ្វើឡើងនៅក្នុងបន្ទប់សវនាការរបស់តុលាការនោះ។

សាលក្រមអាចត្រូវបានសម្រេចនាពេលសវនាការ ដែលធ្វើការពិភាក្សាដេញដោល ឬនៅពេលសវនាការលើកក្រោយ។ ការប្រកាសសាលក្រមត្រូវបានឡើងដោយប្រធានសវនាការដោយកំណត់កាលបរិច្ឆេទយ៉ាងច្បាស់ ពោលគឺអាចនៅពេលបញ្ចប់ការពិភាក្សាដេញដោល ឬប្រកាសនៅថ្ងៃក្រោយដោយកំណត់ថ្ងៃ និងម៉ោងយ៉ាងច្បាស់។

សាលក្រមដែលត្រូវបានប្រកាស គឺត្រូវអានដោយប្រធានសវនាការដោយសម្លេងខ្លាំងៗ ហើយការប្រកាសសាលក្រមនេះត្រូវប្រកាសតែសេចក្តីសម្រេចតែប៉ុណ្ណោះ ពុំចាំចាច់ប្រកាសទាំងសំអាងហេតុនោះទេ។

# សេចក្តីសន្និដ្ឋាន

នៅក្នុងដំណើរការនៃរឿងក្តីព្រហ្មទណ្ឌនៅសាលាដំបូងរាជធានី-ខេត្តនេះ មានដំណាក់កាលនីតិវិធីទៅតាមលំដាប់លំដោយតាមបទបញ្ញត្តិនៃច្បាប់ ហើយបុគ្គលដែលមានសមត្ថកិច្ច ក៏បានបែងចែកមុខងារគ្នាដាច់ដោយឡែកពីគ្នាដែរ។ យើងសង្កេតឃើញមានគោលការណ៍ ដើម្បីធានាប្រសិទ្ធភាពក្នុងការស្វែងរកបទល្មើស និងធ្វើការចោទប្រកាន់ ព្រមទាំងធានាប្រសិទ្ធភាពក្នុងកិច្ចស៊ើបសួរ និងស្វែងរកភស្តុតាងដើម្បីឈានដល់ការជំនុំជម្រះ។

នៅដំណាក់កាលនៃការចោទប្រកាន់ ច្បាប់បានផ្តល់យន្តការឲ្យធ្វើការស៊ើបអង្កេតជាមុនដើម្បីពិនិត្យអំពីអត្ថិភាព ឬនត្ថិភាពនៃបទល្មើសជាមុនព្រមទាំងជាឱកាសសម្រាប់បញ្ជាក់ថា អ្នកណាជាអ្នកប្រព្រឹត្តបទល្មើស អ្នកចូលរួម ព្រមទាំងអ្នកជួយជម្រុញឲ្យមានការប្រព្រឹត្តបទល្មើស ហើយអ្នកដែលមានតួនាទីធ្វើកិច្ចនេះគឺព្រះរាជអាជ្ញា និងមានមន្ត្រីនគរបាលយុត្តិធម៌ជាជំនួយ។ ចំពោះមន្ត្រីនគរបាលយុត្តិធម៌អាចធ្វើការស៊ើបអង្កេតរឿងណាមួយបានដោយត្រូវរាយការណ៍ជូនទៅព្រះរាជអាជ្ញា។ នៅក្នុងក្របខណ្ឌរបស់ខ្លួន មន្ត្រីនគរបាលយុត្តិធម៌មិនអាចតម្កល់រឿងទុកឥតចាត់ការឡើយចំពោះបទល្មើសព្រហ្មទណ្ឌ ទោះបីគូភាគីមានការព្រមព្រៀងគ្នាក៏ដោយ។

ក្រោយពីបានពិនិត្យសំណុំរឿង ព្រះរាជអាជ្ញាមានអំណាចសម្រេចធ្វើការចោទប្រកាន់ ឬមិនចោទប្រកាន់តាមរយៈការតម្កល់រឿងទុកឥតចាត់ការ ដោយយន្តការនេះផ្តល់លទ្ធភាពឲ្យព្រះរាជអាជ្ញាធ្វើការសម្រេចចិត្តទៅតាមកាល្លានុវត្តភាព។ ដោយក្រមនីតិវិធីព្រហ្មទណ្ឌបានផ្តល់អំណាចឲ្យព្រះរាជអាជ្ញាធ្វើការសម្រេចចិត្តទៅតាមសតិសម្បជញ្ញៈ និងចំណេះដឹងដោយឈរលើស្មារតីយុត្តិធម៌ និងដើម្បីផលប្រយោជន៍សង្គម ពោលគឺអាចឲ្យព្រះរាជអាជ្ញាតម្កល់រឿងទុកឥតចាត់ការ ឬធ្វើការចោទប្រកាន់ដោយផ្អែកលើស្ថានភាព និងកាលៈទេសៈនៃអំពើល្មើស។

នៅដំណាក់កាលនៃការស៊ើបសួរ ក្រមនីតិវិធីព្រហ្មទណ្ឌបានផ្តល់អំណាច និងយន្តការនៃការស្រាវជ្រាវផ្សេងៗ ដើម្បីជាប្រយោជន៍សម្តែងឲ្យឃើញការពិតដោយចៅក្រមដែលអាចចេញដីកាផ្សេងៗបាន។ ចៅក្រមស៊ើបសួរមានតួនាទីយ៉ាងចម្បងក្នុងការស្វែងរកភស្តុតាងផ្សេងៗ ក៏ប៉ុន្តែចៅក្រមនេះអាចស៊ើបសួរតែទៅលើអង្គហេតុណាដែលមានចែងក្នុងដីកាបញ្ជូនរឿងឲ្យស៊ើបសួរតែប៉ុណ្ណោះ។ ចៅក្រមស៊ើបសួរធ្វើការស៊ើបសួរទាំងដាក់បន្ទុក និងដោះបន្ទុក ហើយកិច្ចគ្រប់យ៉ាងដើម្បីបញ្ជាក់ឲ្យឃើញការពិត។នៅពេលបញ្ចប់ការស៊ើបសួរចៅក្រមស៊ើបសួរអាចសម្រេចតាមរយៈដីកាដំណោះស្រាយដោយសម្រេចលើកលែងការចោទប្រកាន់ឬធ្វើការចោទប្រកាន់ទៅតាមស្ថានភាពនៃអង្គហេតុ។ ប៉ុន្តែបើដីកានោះជាដីកាលើកលែងការចោទប្រកាន់ ព្រះរាជអាជ្ញា ឬដើមបណ្តឹងរដ្ឋប្បវេណីមានសិទ្ធិប្តឹងឧទ្ធរណ៍ចំពោះដីកានេះបាន ប្រសិនបើណាមិនសុខចិត្តនឹងដីកាសម្រេចនេះ។

ចំណែកនៅដំណាក់កាលនៃការជំនុំជម្រះវិញ គឺជាយន្តការមួយដើម្បីអនុញ្ញាតឲ្យចៅក្រមផ្សេង ពីចៅក្រមដែលបានបើកកិច្ចស៊ើបសួរ ឲ្យធ្វើការវិនិច្ឆ័យទៅលើអង្គសេចក្តី រួមទាំងភស្តុតាងទាំងឡាយដែលប្រមូលបាន។ ដើម្បីទទួលបានប្រសិទ្ធភាពខ្ពស់ក្នុងការផ្តល់យុត្តិធម៌ ក្រមនីតិវិធីព្រហ្មទណ្ឌបានបង្កើតនូវយន្តការដើម្បីឲ្យធ្វើការពិភាក្សាដេញដោលទៅលើគូភាគី។ ចំពោះការបង្កើតឲ្យមានការជំនុំជម្រះឲ្យដាច់ដោយឡែកពីការស៊ើបសួរនេះ គឺដើម្បីឲ្យភាគីកាន់តែទទួលបាននូវភាពយុត្តិធម៌ដែលចៅក្រមស៊ើបសួររឿងក្តីណាមួយហើយមិនអាចជំនុំជម្រះ ឬចូលរួមក្នុងការជំនុំជម្រះរឿងនោះបានទេ ព្រោះចៅក្រមស៊ើបសួរនោះមានបុរេវិនិច្ឆ័យរួចទៅហើយ ក្នុងរឿងដែលខ្លួនបានស្រាវជ្រាវ។

ក្រោយពីបានធ្វើការពិភាក្សាដេញដោលចប់សព្វគ្រប់អស់ហើយ តុលាការសម្រេចទៅលើអង្គសេចក្តីដោយចេញជាសាលក្រម។ នៅគ្រប់សាលក្រមទាំងអស់ភាគីអាចធ្វើការតវ៉ាបានដោយប្តឹងទាស់ចំពោះសាលក្រមកំបាំងមុខ ឬប្តឹងទៅសាលាឧទ្ធរណ៍ករណីសាលក្រមចំពោះមុខ និងចាត់ថាចំពោះមុខ។

ហេតុដូច្នេះហើយ យើងសង្កេតឃើញថា ដំណើរការនៃនីតិវិធីរឿងក្តីព្រហ្មទណ្ឌនេះមានលក្ខណៈល្អិតល្អន់ ហើយច្បាស់លាស់ដែលយន្តការនេះធ្វើឲ្យដំណើរការនៃរឿងក្តីនីមួយៗ មិនអាចទទួលបានភាពឆកល្វែងទេ។ដូចនេះសាលាជម្រះក្តីជាប់ទាបគឺជាប្រភពនៃការផ្តល់យុត្តិធម៌ថ្នាក់ដំបូងជូនប្រជាពលរដ្ឋទូទៅដែលរស់នៅក្នុងសង្គម។

# អនុសាសន៍

នៅក្នុងគោលការណ៍ច្បាប់គឺ បានបញ្ញត្តិយ៉ាងច្បាស់ទាក់ទងនឹងដំណើរការនៃនីតិវិធីទាំងអស់នេះ ក៏ប៉ុន្តែបើយើងក្រឡេកមកមើលការអនុវត្តជាក់ស្តែងវិញ យើងឃើញថាវានៅមានភាពខ្វះចន្លោះនៅឡើយ ដោយមន្ត្រីមួយចំនួនមិនបានបំពេញកាតព្វកិច្ចរបស់ខ្លួនឲ្យបានខ្ជាប់ខ្ជួននោះទេនៅក្នុងប្រព័ន្ធយុត្តាធិការនេះ។ ជាពិសេសមន្ត្រីនគរបាលយុត្តិធម៌មួយចំនួនហាក់ដូចជាមិនទាន់បានយល់ច្បាស់អំពីនីតិវិធីទាំងអស់នេះឲ្យបានទូលំទូលាយនៅឡើយទេ ព្រោះយើងសង្កេតឃើញថាមន្ត្រីនគរបាលយុត្តិធម៌មួយចំនួនធ្វើការបិទសំណុំរឿងនៅនឹងមូលដ្ឋានជាច្រើនករណីក្រោមរូបភាពធ្វើជាមជ្ឈត្តករក្នុងការសម្រុះសម្រួល។ កត្តាទាំងនេះហើយដែលជាចលករមួយធ្វើឲ្យសង្គមមានភាពអនាធិបតេយ្យ ខ្វះស្ថេរភាព អសន្តិសុខ មិនគោរពច្បាប់ជាដើម។ នេះបណ្តាលមកពីមន្ត្រីទាំងនោះមិនមានលក្ខណៈសម្បត្តិគ្រប់គ្រាន់ជាអ្នកស្វែងរកយុត្តិធម៌ជូនប្រជាពលរដ្ឋ ហើយវាក៏ជាកត្តាមួយធ្វើឲ្យប្រជាពលរដ្ឋអស់ជំនឿលើប្រព័ន្ធយុត្តាធិការ មិនត្រឹមតែប៉ុណ្ណោះវាក៏ផ្ទុយទៅនឹងគោលការណ៍ប្រជាធិបតេយ្យដែលប្រទេសកម្ពុជាបច្ចុប្បន្នកំពុងប្រកាន់យកក្នុងទិសដៅជម្រុញឲ្យប្រទេសជាតិក្លាយជានីតិរដ្ឋមួយយ៉ាងពិតប្រាកដ។

ហេតុដូច្នេះហើយ ដើម្បីបញ្ចៀសបាតុភាពអសកម្មមួយចំនួននេះ រាជរដ្ឋាភិបាលគួរតែចាត់វិធានការពង្រឹងវិស័យអប់រំ បណ្តុះបណ្តាលមន្ត្រីផ្នែកប្រព័ន្ធយុត្តាធិការឲ្យមានឯកទេស និងជំនាញឲ្យបានច្បាស់លាស់ជៀសវាងមន្ត្រីទាំងនោះធ្វើការវិនិច្ឆ័យសេចក្តីដោយភាពអគតិទាំងឡាយដែលនាំឲ្យមានភាពអយុត្តិធម៌ទៅលើជនដែលមិនបានប្រព្រឹត្តកំហុស។

# ឯកសារពិគ្រោះ


១. រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា ប្រកាសឲ្យប្រើថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ១៩៩៣

២. ក្រមនីតិវិធីព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា អនុម័តនៅថ្ងៃទី០៧ ខែមិថុនា ឆ្នាំ២០០៧

៣. ក្រមព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា អនុម័តដោយរដ្ឋសភា នៅថ្ងៃទី១២ ខែតុលា ឆ្នាំ២០០៩ និង ដោយព្រឹទ្ធសភា នៅថ្ងៃទី១៧ ខែវិច្ឆិកា ឆ្នាំ២០០៩ និង បានប្រកាសឲ្យប្រើដោយព្រះរាជក្រមលេខនស\រកម\១១០៩\០២២ ចុះថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ២០០៦ ។

៤. ច្បាប់ស្តីពីការធ្វើវិសោធនកម្មមាត្រា ៥១ នៃច្បាប់ស្តីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិល

៥. សៀវភៅមេរៀនស្តីពីនីតិវិធីព្រហ្មទណ្ឌលោកសាស្ត្រាចារ្យ រុន ពណ្ណរិទ្ធ លោកស្រីសាស្ត្រាចារ្យចាំង ស៊ីណាត បោះពុម្ពនៅឆ្នាំ២០១៣ ។

៦. វចនានុក្រមសម្តេចព្រះសង្ឃរាជ ជួន ណាត

៧. វចនានុក្រមច្បាប់ ដែលបោះពុម្ពលើកទី៤ ឆ្នាំ២០១៤ របស់លោក ហ៊ីង ធីឫទ្ធិ។

# ឧបសម្ព័ន្ធ

# តារាងឧបសម្ព័ន្ធ

១. ពាក្យបណ្ដឹង

២. ដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរ

៣. កំណត់ហេតុប្រគល់វត្ថុតាង

៤. ដីកាសម្រេចអនុញ្ញាតឲ្យនៅក្រៅឃុំបណ្ដោះអាសន្ន

៥. ដីកាសម្រេចឲ្យឃុំខ្លួនបណ្ដោះអាសន្ន

៦. ដីកាសម្រេចមិនឃុំខ្លួនបណ្ដោះអាសន្ន

៧. ដីកាកោះ

៨. ដីកាបង្គាប់ឲ្យចូលខ្លួន

៩. ដីកាបង្គាប់ឲ្យនាំខ្លួន

១០. ដីកាបង្គាប់ឲ្យចាប់ខ្លួន

១១. ដីកាបង្គាប់ឲ្យឃុំខ្លួន

១២. ដីកាបញ្ជូនរឿងមូលទៅពិនិត្យ

១៣. ដីកាសម្រេចបញ្ជូនសំណុំរឿងទៅជំនុំជម្រះ

១៤. ដីកាដំណោះស្រាយបញ្ជូនរឿងទៅជំនុំជម្រះ

១៥. ដីកាបញ្ជូនរឿងទៅជំនុំជម្រះ

១៦. ដីកាសម្រេចបញ្ជូនរឿងទៅជំនុំជម្រះ

១៧. បទបញ្ជាផ្ទៃក្នុងនៃបន្ទប់ជំនុំជម្រះ

១៨. ដីកាសន្និដ្ឋានស្ថាពរ

១៩. ច្បាប់ស្ដីពីការធ្វើវិសោធនកម្មមាត្រា៥១ នៃច្បាប់ស្ដីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិល ។